ច្បាប់ចម្លង

# ព្រះរាជក្រម

នស/រកម/០៧២៣/ ០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយ ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# អត្រានុកូលដ្ឋាន
# ស្ថិតិអត្រានុកូលដ្ឋាន
# និងអត្តសញ្ញាណកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.- គោលបំណង**

ច្បាប់នេះកំណត់អំពីវិធាននិងនីតិវិធីដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការរៀបចំស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គលនិងការរៀបចំនិងការគ្រប់គ្រងបញ្ជីប្រជាជន ក្នុងគោលបំណងដើម្បី៖

ក- ធានាឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

ខ- ធានាឱ្យមានការចុះបញ្ជីអត្តសញ្ញាណបុគ្គលជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

គ- ធានាថាការចុះបញ្ជីស្នាក់នៅ ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

ឃ- ធានាឱ្យមនុស្សគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាននិងការចុះបញ្ជីអត្តសញ្ញាណ ដោយផ្តល់ចំពោះបុគ្គលម្នាក់ៗនូវលេខសម្គាល់អត្តសញ្ញាណបុគ្គល។

ង- ធានានូវការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍និងការតាមដានភាពរីកចម្រើននៃសង្គម។

**មាត្រា២.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះជនគ្រប់រូបដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស។

**មាត្រា៣.- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ការចុះបញ្ជីអត្រានុកូលដ្ឋាន

### ផ្នែកទី១
### វិធានទូទៅ

**មាត្រា៤.- ព្រឹត្តិការណ៍ជីវិតដែលត្រូវចុះបញ្ជី**

ព្រឹត្តិការណ៍ជីវិតដែលតម្រូវឱ្យចុះបញ្ជី រួមមានកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

២- ក្រៅពីព្រឹត្តិការណ៍ជីវិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ព្រឹត្តិការណ៍ជីវិតផ្សេងទៀតក៏ត្រូវចុះបញ្ជីផងដែរ រួមមានការទទួលស្គាល់កូន ការបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព សុំកូន ការកាត់កាល់កូនសុំ ការលែងលះ មោឃភាពអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ និងព្រឹត្តិការណ៍ជីវិតផ្សេងទៀតដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតម្រូវឱ្យចុះបញ្ជីស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ផ្នែកទី២
## បញ្ជីអត្រានុកូលដ្ឋាន

### មាត្រា៥.- ប្រភេទបញ្ជីអត្រានុកូលដ្ឋាន

បញ្ជីអត្រានុកូលដ្ឋាន រួមមានបញ្ជីកំណើតរស់ បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍។

### មាត្រា៦.- ទម្រង់បញ្ជីអត្រានុកូលដ្ឋាន

១- បញ្ជីអត្រានុកូលដ្ឋានអាចរក្សាទុកក្នុងទម្រង់ជាក្រដាសនិង/ឬទម្រង់អេឡិចត្រូនិក។

២- ទម្រង់និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាននិងទម្រង់ប្រើប្រាស់ដើម្បីជូនដំណឹង រាយការណ៍និងចុះបញ្ជីព្រឹត្តិការណ៍ជីវិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកចែងនៅក្នុងច្បាប់នេះ។

## ផ្នែកទី៣
## មន្ត្រីអត្រានុកូលដ្ឋាន

### មាត្រា៧.- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

១- អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

២- ក្នុងករណីដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃអវត្តមាន អគ្គនាយករងម្នាក់ដែលទទួលសិទ្ធិជាអគ្គនាយកស្ដីទីមានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

### មាត្រា៨.- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលអភិបាលនៃគណៈអភិបាលរាជធានី ខេត្តអវត្តមាន អភិបាលរងរាជធានី ខេត្ត ដែលទទួលសិទ្ធិជាអភិបាលស្ដីទីនៃគណៈអភិបាលរាជធានី ខេត្ត មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

**មាត្រា៩ ._ មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ**

១- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌអវត្តមាន អភិបាលរងក្រុង ស្រុក ខណ្ឌ ដែលទទួលសិទ្ធិជាអភិបាលស្តីទីនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត។

**មាត្រា១០ ._ មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់**

១- មេឃុំ ចៅសង្កាត់ ជាមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន មេឃុំ ចៅសង្កាត់ ត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកជំនួយការមេឃុំ ចៅសង្កាត់តាមឋានានុក្រម និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ។

៣- ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមានដោយសារមរណភាពឬការបញ្ឈប់មុខតំណែង ក្នុងរយៈពេលអន្តរកាលដែលមិនទាន់មានការតែងតាំងមេឃុំ ចៅសង្កាត់ថ្មី មេឃុំ ចៅសង្កាត់ស្តីទី គឺជាមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់។

**មាត្រា១១ ._ មន្ត្រីអគ្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា**

រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់តាំងមន្ត្រី១(មួយ)រូបជាមន្ត្រីអគ្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស និងត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីការចាត់តាំងនេះ។

## ផ្នែកទី៤
## សមត្ថកិច្ចនៃមន្ត្រីអគ្រានុកូលដ្ឋាន

**មាត្រា១២ ._ សមត្ថកិច្ចនៃមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ជាតិ**

មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ជាតិ មានសមត្ថកិច្ចដូចខាងក្រោម៖

ក- គ្រប់គ្រងនិងរក្សាទុកបញ្ជីអគ្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួច។

ខ- ធានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអគ្រានុកូលដ្ឋានដែលស្ថិតនៅក្រោមច្បាប់នេះ។

គ- ដាក់ចេញគោលការណ៍ សេចក្តីណែនាំនិងបែបបទនិងនីតិវិធីស្របតាមការកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

ឃ- ត្រួតពិនិត្យនិងណែនាំដល់មន្ត្រីអគ្រានុកូលដ្ឋានគ្រប់ថ្នាក់ រួមទាំងមន្ត្រីអគ្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសលើការអនុវត្តការងារអគ្រានុកូលដ្ឋាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ង- អភិវឌ្ឍផែនការនិងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន។

ច- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ឆ- រាយការណ៍រាល់ករណីរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋាន ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការតាមច្បាប់។

ជ- ពិនិត្យសម្រេចនិងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ឈ- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ផ្សេងទៀតមិនអាចសម្រេចបាន។

ញ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានគ្រប់លំដាប់ថ្នាក់និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ដ- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានការស្នើសុំ។

ឋ- ក្នុងករណីដែលចាំបាច់ ស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការបង្កើតការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៅមូលដ្ឋានសុខាភិបាលឬកន្លែងផ្សេងទៀតដែលព្រឹត្តិការណ៍ជីវិតអាចកើតឡើង ដោយរៀបចំឱ្យមានបុគ្គលិកអត្រានុកូលដ្ឋានឬធ្វើប្រតិភូកម្មភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានទៅឱ្យមន្ត្រីសុខាភិបាល។

ឌ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៣.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍តាមការស្នើសុំ។

ខ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

គ- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់នេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឃ- អភិវឌ្ឍផែនការនិងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ង- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ច- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មិនអាចសម្រេចបាន។

ឆ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៤.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ខ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

គ- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់នេះ។

ឃ- គាំទ្រនិងពង្រឹងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ង- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ច- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មិនអាចសម្រេចបាន។

ឆ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា១៥ ._ សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ចដូចខាងក្រោមៈ

ក- ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមនិងសេចក្តីចម្លង។

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានយោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- ផ្តល់ការអនុញ្ញាតសម្រាប់ការបូជាសពឬការបញ្ចុះសព។

ង- កត់ត្រា កែតម្រូវ ឬធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចជាស្ថាពររបស់តុលាការនិង/ឬទៅតាមការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើដែលមានអានុភាពអនុវត្ត។

ច- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវទៅតាមការកំណត់។

ឆ- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាននិងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន មន្ត្រីសុខាភិបាល មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច និងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត អំពីការងារអត្រានុកូលដ្ឋាន ក្នុងករណីដែលចាំបាច់។

ឈ- ចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវការចុះបញ្ជីអត្រានុកូលដ្ឋានពេញលេញ។

ញ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

## មាត្រា១៦ ._ សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចដូចខាងក្រោមៈ

ក- ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមនិងសេចក្តីចម្លង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវទៅតាមការកំណត់។

ង- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៥
## ការចុះបញ្ជីកំណើតរស់

### មាត្រា១៧._ ការចុះបញ្ជីកំណើតរស់

រាល់កំណើតរស់ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍និងចុះបញ្ជីដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

### មាត្រា១៨._ ទីកន្លែងចុះបញ្ជីកំណើតរស់

អ្នករាយការណ៍ ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ នៅការិយាល័យអត្រានុកូលដ្ឋានណាមួយនេះ

ក- ឃុំ សង្កាត់ ដែលកំណើតរស់បានកើតឡើង។

ខ- ឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ។

គ- កន្លែងផ្សេងទៀត តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

### មាត្រា១៩._ រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលទារកកើត។

២- ក្រសួងមហាផ្ទៃអាចពន្យាររយៈពេលកំណត់នៃការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់សម្រាប់ភូមិសាស្ត្រជាក់លាក់ ឬក្រុមជនជាតិដើមភាគតិច ឬដោយសារមូលហេតុផ្សេងទៀត ក្នុងករណីដែលចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា២០._ អ្នករាយការណ៍អំពីកំណើតរស់

១- បុគ្គលទទួលខុសត្រូវជាអ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

ក- ម្តាយរបស់ទារក។

ខ- ឪពុករបស់ទារក។

គ- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្តាយទារក។

ឃ- ញាតិជានីតិជនដែលមើលថែទារក។

ង- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាងឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់នេះឬច្បាប់ផ្សេងទៀត។

២- ក្នុងករណីដែលមានការចាំបាច់ អ្នករាយការណ៍ក្រៅពីបុគ្គលដែលបានកំណត់ខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា២១ .- ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល

១- ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលកំណើតរស់បានកើតឡើង ត្រូវផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ទៅឱ្យអ្នករាយការណ៍ទៅតាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ។

២- ប្រសិនបើទារកកើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយនិងទារកធ្វើដំណើរទៅមូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ឱ្យទៅអ្នករាយការណ៍ទៅតាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្ញើច្បាប់ចម្លងនៃឯកសារបញ្ជាក់អំពីកំណើតរស់នោះមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៤- ទម្រង់ របៀបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## មាត្រា២២ .- ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាល

ប្រសិនបើកំណើតរស់កើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយនិងទារកមិនបានធ្វើដំណើរទៅកាន់មូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង បុគ្គលឬស្ថាប័នដែលបានដឹងពីព្រឹត្តិការណ៍កំណើតរស់នេះ អាចតម្រូវឱ្យផ្តល់ព័ត៌មានឬឯកសារដូចមានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## មាត្រា២៣ .- ពាក្យសុំចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ឬតាមទម្រង់អេឡិចត្រូនិក។

២- ក្នុងពាក្យសុំចុះបញ្ជីកំណើតរស់ អ្នករាយការណ៍ត្រូវបំពេញពាក្យសុំនូវចំណុចខាងក្រោម៖

ក- ឈ្មោះរបស់ទារក។

ខ- ភេទរបស់ទារក។

គ- ថ្ងៃ ខែ ឆ្នាំកំណើត ម៉ោងនិងទីកន្លែងទារកកើតរស់។

ឃ- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សញ្ជាតិ និងលំនៅឋានរបស់ឪពុកម្ដាយរបស់ទារក។

ង- ឈ្មោះថ្ងៃ ខែឆ្នាំកំណើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនិងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍ ក្នុងករណីដែលអ្នករាយការណ៍មិនមែនជាម្ដាយ ឬឪពុក។

ច- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។

ឆ- ចំណុចផ្សេងទៀត ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ទម្រង់និងបែបបទនៃពាក្យសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## មាត្រា២៤.- ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីកំណើតរស់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ឬកថាខណ្ឌទី២នៃមាត្រា២១(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល) នៃច្បាប់នេះ ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។ ប្រសិនបើអ្នករាយការណ៍មិនមានឯកសារបញ្ជាក់អំពីកំណើតរស់នោះទេ អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារក។

២- អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្ដាយរបស់ទារកជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។

៣- ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារកដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី២នៃកថាខណ្ឌទី១និងឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្ដាយរបស់ទារកដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## មាត្រា២៥.- នីតិវិធីចុះបញ្ជីកំណើតរស់

១- នៅពេលទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់និងឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា២៣(ពាក្យសុំចុះបញ្ជីកំណើតរស់) និងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងកត់ត្រាព័ត៌មាននោះទៅក្នុងបញ្ជីកំណើតរស់។

២- ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីកំណើតរស់ រួមមានឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកកើត។

៣- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីកំណើតរស់ខ្វះនូវព័ត៌មានណាមួយក្នុងចំណោមព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ មន្ត្រី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អគ្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានដែលខ្វះនោះ ដោយកំណត់រយៈពេលសមរម្យ។ ក្នុងករណីដែលអ្នករាយការណ៍មិនផ្តល់ព័ត៌មានដែលខ្វះក្នុងរយៈពេលសមរម្យដែលបានកំណត់ដោយមន្ត្រីអគ្រានុកូលដ្ឋាន មន្ត្រីអគ្រានុកូលដ្ឋានអាចលើកចោលពាក្យសុំចុះបញ្ជីកំណើតរស់នោះ។

៤- មន្ត្រីអគ្រានុកូលដ្ឋានមិនត្រូវបដិសេធពាក្យសុំចុះបញ្ជីកំណើតរស់ ដោយសារខ្វះព័ត៌មានដែលទាក់ទងទៅនឹងឪពុកឬម្តាយឡើយ។

៥- ប្រសិនបើមន្ត្រីអគ្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីកំណើតរស់ដែលខ្វះនូវព័ត៌មានមួយចំនួនក្នុងចំណោមចំណុចនីមួយៗ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២នៃមាត្រា២៣ (ពាក្យសុំចុះបញ្ជីកំណើតរស់) ក្រៅពីព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ឬខ្វះឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ មន្ត្រីអគ្រានុកូលដ្ឋានត្រូវចុះបញ្ជីកំណើតរស់តាមព័ត៌មានដែលមាននោះ។ ក្នុងករណីនេះ មន្ត្រីអគ្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានបន្ថែម ដោយកំណត់រយៈពេលសមរម្យ ។

៦- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី៤ខាងលើនេះក៏ដោយ មន្ត្រីអគ្រានុកូលដ្ឋានអាចចុះបញ្ជីដោយឆន្ទានុសិទ្ធិឬដោយទទួលការអនុញ្ញាតពីមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់លើ ប្រសិនបើមន្ត្រីអគ្រានុកូលដ្ឋានបានទទួលព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ តាមការជូនដំណឹងពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឬវិធីផ្សេងទៀត។

## មាត្រា២៦.- ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- ក្រោយពេលមន្ត្រីអគ្រានុកូលដ្ឋានទទួលយកនិងកត់ត្រាព័ត៌មានទាក់ទងនឹងកំណើតរស់រួចមក មន្ត្រីអគ្រានុកូលដ្ឋានត្រូវស្នើទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនដូចមានចែងនៅក្នុងជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ ដើម្បីផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដល់អ្នកកើត។

២- ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវអនុវត្តទៅតាមជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ។

៣- ក្រោយពេលទទួលបានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល មន្ត្រីអគ្រានុកូលដ្ឋានត្រូវប្រគល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់អ្នកកើតនោះទៅឱ្យអ្នករាយការណ៍។

## មាត្រា២៧.- សំបុត្រកំណើត

១- ក្រោយពេលបានចុះបញ្ជីកំណើតរស់រួចរាល់ មន្ត្រីអគ្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រកំណើតច្បាប់ដើម១(មួយ)ច្បាប់ជូនអ្នករាយការណ៍ដោយឥតគិតថ្លៃ។

២- ព័ត៌មាននៅលើសំបុត្រកំណើតច្បាប់ដើម រួមមាន៖

ក- ឈ្មោះរបស់អ្នកកើត។

ខ- ភេទរបស់អ្នកកើត។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

គ- ឈ្មោះឪពុកនិង/ឬម្ដាយរបស់អ្នកកើត។

ឃ- ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកកើត។

ង- ព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា២៨.- សេចក្ដីចម្លងសំបុត្រកំណើតនិងសម្រង់បញ្ជីកំណើត**

១- បុគ្គលដែលអាចស្នើសុំសេចក្ដីចម្លងសំបុត្រកំណើតបាន រួមមាន៖

ក- សាមីខ្លួននៃសំបុត្រកំណើត។

ខ- ញាតិលោហិតផ្ទាល់និងសហព័ទ្ធរបស់សាមីខ្លួននៃសំបុត្រកំណើត។

គ- អ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ ដូចមានចែងនៅក្នុងចំណុច ក និងខ។

ឃ- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថា បុគ្គលស្នើសុំសេចក្ដីចម្លងសំបុត្រកំណើតមិនមែនជាបុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើ ឬការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវ ដូចជាគោលបំណងធ្វើឱ្យមានការប៉ះពាល់ភាពឯកជនរបស់សាមីខ្លួននៃសំបុត្រកំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះ និងត្រូវផ្ដល់មូលហេតុសម្រាប់ការបដិសេធនោះ។ ការបដិសេធនេះអាចប្ដឹងមិនសុខចិត្តបាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី១៣ (បណ្ដឹងមិនសុខចិត្ត) នៃជំពូកនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្ដីចម្លងសំបុត្រកំណើតឬសម្រង់បញ្ជីកំណើត ក្នុងករណីដែលមានការចាំបាច់ ដើម្បីបំពេញកិច្ចការរបស់ខ្លួនដោយផ្អែកលើច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្ដល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។

**មាត្រា២៩.- ទម្រង់សំបុត្រកំណើតនិងសេចក្ដីចម្លងសំបុត្រកំណើត**

១- សំបុត្រកំណើតនិងសេចក្ដីចម្លងសំបុត្រកំណើត ត្រូវមានលក្ខណៈសម្គាល់ធានាសុវត្ថិភាពដើម្បីការពារការក្លែងបន្លំ។

២- ទម្រង់សំបុត្រកំណើតនិងសេចក្ដីចម្លងសំបុត្រកំណើត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣០.- ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលគេបោះបង់**

១- ប្រសិនបើជនណាម្នាក់រើសបានទារកនៅរស់ដែលត្រូវគេបោះបង់ចោល ជននោះត្រូវផ្ដល់ព័ត៌មានអំពីព្រឹត្តិការណ៍នោះទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃឃុំ សង្កាត់ដែលទារកត្រូវបានរើសបានដោយគ្មានការយឺតយ៉ាវ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ជនដែលរើសបានទារកនៅរស់នោះ ត្រូវផ្តល់៖

ក- កាលបរិច្ឆេទនិងទីកន្លែងដែលខ្លួនរើសបានទារក។

ខ- ភេទរបស់ទារក។

គ- ការប៉ាន់ស្មានអំពីថ្ងៃខែឆ្នាំកំណើតរបស់ទារក ប្រសិនបើអាច។

ឃ- ឈ្មោះនិងលំនៅឋានរបស់ជនដែលរើសបានទារក។

៣- ក្រោយពេលទទួលបានព័ត៌មានក្នុងកថាខណ្ឌទី២ខាងលើ មន្ត្រីអត្រានុកូលដ្ឋានត្រូវកត់ត្រាព័ត៌មាននិងចុះបញ្ជីកំណើតរស់របស់ទារកនោះ ដោយកំណត់ឈ្មោះទារក ទោះបីគ្មានអ្នករាយការណ៍ដាក់ពាក្យសុំក៏ដោយ។ ក្នុងករណីដែលចាំបាច់ ប្រសិនបើការប៉ាន់ស្មានអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារកមិនអាចធ្វើបានទេ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះជាមួយមន្ត្រីសុខាភិបាលដើម្បីកំណត់ថ្ងៃខែឆ្នាំកំណើតរបស់ទារកដែលរើសបាន។ ប្រសិនបើទីកន្លែងកំណើតរបស់ទារកមិនច្បាស់លាស់ ទីកន្លែងរបស់ទារកដែលរើសបាននោះ ត្រូវសន្មតថាជាទីកន្លែងកំណើតរបស់ទារក។

៤- ក្រោយពេលទារកនោះត្រូវបានចុះបញ្ជីកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃកន្លែងដែលទារកត្រូវបានរើសបាន ត្រូវបញ្ជូនទារកនោះទៅមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារដោយភ្ជាប់ជាមួយសំបុត្រកំណើតដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។

៥- អ្នកអាណាព្យាបាលសម្រាប់អនីតិជនចំពោះទារកដែលត្រូវបានរើសបាន អាចដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ដើម្បីកែប្រែឬបំពេញបន្ថែមព័ត៌មានរបស់ទារកទៅក្នុងបញ្ជីកំណើតរស់របស់ទារកនោះ។ បញ្ញត្តិនៃផ្នែកទី១០(ការកែបញ្ជីអត្រានុកូលដ្ឋាន) នៃជំពូកនេះមិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ។

៦- ទារកដែលរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសន្មតថាមានសញ្ជាតិខ្មែរពីកំណើត។

**មាត្រា៣១.- មោឃភាពបញ្ជីកំណើតរស់របស់ទារកដែលគេបោះបង់**

ក្នុងករណីដែលទារកដែលគេបោះបង់បានចុះបញ្ជីកំណើតរស់ ដោយអនុលោមតាមមាត្រា៣០ (ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលគេបោះបង់) នៃច្បាប់នេះ ប៉ុន្តែក្រោយមក ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានរកឃើញថាទារកនោះធ្លាប់បានចុះបញ្ជីកំណើតរស់ពីមុនរួចហើយ បញ្ជីកំណើតថ្មីដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់នេះត្រូវទុកជាមោឃៈ ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវដកហូតសំបុត្រកំណើតថ្មីនោះនិងសេចក្តីចម្លងសំបុត្រកំណើតថ្មីដែលបានចេញកន្លងមកនោះ។

**មាត្រា៣២.- ការចុះបញ្ជីកំណើតរស់សម្រាប់កុមារក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ**

១- ការចុះបញ្ជីកំណើតរស់សម្រាប់កុមារក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ត្រូវអនុវត្តទៅតាមមាត្រា២៣(ពាក្យសុំចុះបញ្ជីកំណើតរស់) មាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់) និងមាត្រា២៥(នីតិវិធីចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ។

២- ប្រធានមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ត្រូវធានាថាកុមារទាំងអស់ដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារនោះ ត្រូវបានចុះបញ្ជីកំណើតរស់។ ប្រធានមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាអ្នករាយការណ៍ ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ។

## មាត្រា៣៣ .- មោឃភាពការចុះបញ្ជីកំណើតរស់របស់កុមារក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ

ក្នុងករណីដែលកុមារនៅក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារបានចុះបញ្ជីកំណើតរស់ដោយអនុលោមតាមមាត្រា៣២(ការចុះបញ្ជីកំណើតរស់សម្រាប់កុមារក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ) នៃច្បាប់នេះរួចហើយ ប៉ុន្តែក្រោយមកប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានរកឃើញថាកុមារនោះធ្លាប់បានចុះបញ្ជីកំណើតរស់ពីមុនរួចហើយ បញ្ជីកំណើតថ្មីដែលបានបង្កើតឡើងដោយអនុលោមតាមច្បាប់នេះត្រូវទុកជាមោឃៈ ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវដកហូតសំបុត្រកំណើតថ្មីនិងសេចក្តីចម្លងសំបុត្រកំណើតថ្មីដែលបានចេញកន្លងមកនោះ។

## មាត្រា៣៤ .- ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលកើតពីស្ត្រីជាជនជាប់ឃុំក្នុងពន្ធនាគារឬមណ្ឌលយុវនីតិសម្បទា

ប្រធានពន្ធនាគារឬប្រធានមណ្ឌលយុវនីតិសម្បទា ត្រូវធានាថាទារកទាំងអស់ដែលកើតពីស្ត្រីជាជនជាប់ឃុំក្នុងពន្ធនាគារឬមណ្ឌលយុវនីតិសម្បទា ត្រូវបានចុះបញ្ជីកំណើតរស់។ ប្រធានពន្ធនាគារឬប្រធានមណ្ឌលយុវនីតិសម្បទា ត្រូវមានតួនាទីជាអ្នករាយការណ៍។

## មាត្រា៣៥ .- ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលកើតក្នុងយានជំនិះកំពុងធ្វើដំណើរ

១- ប្រសិនបើស្ត្រីណាម្នាក់ដែលកំពុងធ្វើដំណើរមកព្រះរាជាណាចក្រកម្ពុជាឬនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរថភ្លើង នាវា អាកាសយាន ឬយានជំនិះសាធារណៈផ្សេងទៀត បានសម្រាលកូននៅលើយានជំនិះនោះ ឃុំ សង្កាត់ដែលរថភ្លើង នាវា អាកាសយាន ឬយានជំនិះនោះឈប់សំចត ហើយម្តាយចុះពីយានជំនិះក្រោយពេលសម្រាល ត្រូវចាត់ទុកជាទីកន្លែងដែលព្រឹត្តិការណ៍កំណើតរស់បានកើតឡើង។

២- ប្រសិនបើស្ត្រីណាម្នាក់ដែលមានសញ្ជាតិខ្មែរ ហើយកំពុងធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជាតាមរថភ្លើង នាវា អាកាសយាន ឬយានជំនិះសាធារណៈផ្សេងទៀត បានសម្រាលកូននៅលើយានជំនិះនោះ ទីកន្លែងដែលរថភ្លើង នាវា អាកាសយាន ឬយានជំនិះនោះឈប់សំចត ហើយម្តាយចុះពីយានជំនិះ ក្រោយពេលសម្រាល ត្រូវចាត់ទុកជាទីកន្លែងដែលព្រឹត្តិការណ៍កំណើតរស់បានកើតឡើង។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ អ្នករាយការណ៍ត្រូវចុះបញ្ជីកំណើតរស់នៅទីកន្លែងណាមួយដូចមានកំណត់នៅក្នុងមាត្រា១៨( ទីកន្លែងចុះបញ្ជីកំណើតរស់ ) នៃច្បាប់នេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា៣៦.- ការរាយការណ៍អំពីកំណើតរស់របស់ទារកនៃប្រជាពលរដ្ឋខ្មែរ ដែលកើតនៅក្រៅព្រះរាជាណាចក្រកម្ពុជា

១- ប្រសិនបើប្រជាពលរដ្ឋខ្មែរផ្តល់កំណើតឱ្យទារកនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នករាយការណ៍ ដូចមានកំណត់នៅក្នុងមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នេះទៅមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមត្ថកិច្ចនៅប្រទេសដែលទារកកើត ដោយផ្តល់ឯកសារភ្ជាប់ទាំងអស់ដូចខាងក្រោម៖

- ក- ភស្តុតាងបញ្ជាក់អំពីកំណើតរស់ឬសំបុត្រកំណើតពីប្រទេសដែលទារកកើត។
- ខ- ឯកសារភ្ជាប់ផ្សេងទៀត ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

២- ប្រសិនបើគ្មានស្ថានតំណាង ឬពុំអាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ ឬពុំមានលទ្ធភាពចុះបញ្ជីកំណើតរស់ទៅមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងប្រទេសនោះ អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ក្រោយពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ដោយផ្តល់ឯកសារភ្ជាប់ទាំងអស់ដូចខាងក្រោម៖

- ក- ភស្តុតាងបញ្ជាក់អំពីកំណើតរស់ឬសំបុត្រកំណើតពីប្រទេសដែលទារកកើត។
- ខ- ឯកសារភ្ជាប់ផ្សេងទៀត ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវកត់ត្រាអំពីព្រឹត្តិការណ៍កំណើតរស់និងចេញសំបុត្រកំណើត ដោយអនុលោមតាមមាត្រា២៥(នីតិវិធីចុះបញ្ជីកំណើតរស់) និងមាត្រា២៧(សំបុត្រកំណើត) នៃច្បាប់នេះ។

## មាត្រា៣៧.- ការចុះបញ្ជីកំណើតរស់របស់ទារកដែលកើតពីឪពុកម្តាយជាជនបរទេស

កំណើតរស់របស់ទារកដែលកើតពីឪពុកម្តាយជាជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃផ្នែកទី៥(ការចុះបញ្ជីកំណើតរស់) នៃជំពូកនេះ។

## មាត្រា៣៨.- ការចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះមួយឆ្នាំ

១- ប្រសិនបើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទារកកើតឬរយៈពេលផ្សេងទៀតដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា១៩(រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ អ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃដែលទារកកើត។ អ្នករាយការណ៍ក៏ត្រូវបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃឬរយៈពេលផ្សេងទៀតដូចមានកំណត់ក្នុងមាត្រា១៩(រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ ក្រោយពេលទារកនោះកើត។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

២- នៅពេលមន្ត្រីអត្រានុកូលដ្ឋានបានទទួលពាក្យសុំចុះបញ្ជី ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីកំណើតរស់ដោយអនុលោមតាមមាត្រា២៥(នីតិវិធីចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ។ មន្ត្រីអត្រានុកូលដ្ឋានមិនអាចបដិសេធពាក្យសុំចុះបញ្ជីកំណើតរស់ដោយផ្អែកលើមូលហេតុនៃការពន្យល់អំពីការយឺតយ៉ាវក្នុងការដាក់ពាក្យសុំចុះបញ្ជីនោះឡើយ។

**មាត្រា៣៩.- ការចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ**

១- ប្រសិនបើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្រោយផុតរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ ក្រៅពីឯកសារភ្ជាប់ដូចមានចែងនៅក្នុងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ អ្នករាយការណ៍ត្រូវផ្ដល់ព័ត៌មានឬឯកសារបន្ថែមណាមួយដូចខាងក្រោម៖

ក- ការធានាអះអាងនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរបស់សាក្សីនៃកំណើតរស់នេះ។

ខ- បណ្ណសុខភាពកុមារ។

គ- ឯកសារឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់អំពីព្រឹត្តិការណ៍កំណើតរស់ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

២- នៅពេលទទួលបានព័ត៌មាននិងឯកសារដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីកំណើតរស់នោះ។ មន្ត្រីអត្រានុកូលដ្ឋានមិនអាចបដិសេធពាក្យសុំចុះបញ្ជីកំណើតរស់ដោយសារផុតរយៈពេលអនុគ្រោះឡើយ។

**មាត្រា៤០.- ការដាស់តឿននិងការចុះបញ្ជីកំណើតរស់ចល័តតាមមូលដ្ឋាន**

១- នៅពេលមន្ត្រីអត្រានុកូលដ្ឋានដឹងថាមានព្រឹត្តិការណ៍កំណើតរស់មួយបានកើតឡើងតាមរយៈការជូនដំណឹងពីអាជ្ញាធរពាក់ព័ន្ធឬប្រភពផ្សេងទៀត ហើយមន្ត្រីអត្រានុកូលដ្ឋានដឹងថាអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់នៅឡើយនោះ មន្ត្រីអត្រានុកូលដ្ឋានត្រូវដាស់តឿនដល់អ្នករាយការណ៍ឱ្យដាក់ពាក្យសុំចុះបញ្ជី ដោយកំណត់រយៈពេលសមស្រប។

២- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ អាចចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីចុះបញ្ជីកំណើតរស់ដែលមិនទាន់បានចុះបញ្ជីកន្លងមក ដោយអនុលោមតាមបញ្ញត្តិនៃផ្នែកទី៥(ការចុះបញ្ជីកំណើតរស់) នៃជំពូកនេះ។

## ផ្នែកទី៦
## ការចុះបញ្ជីមរណភាព

**មាត្រា៤១.- ការចុះបញ្ជីមរណភាព**

រាល់មរណភាពដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍និងចុះបញ្ជីដោយស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

### មាត្រា៤២.- ទីកន្លែងចុះបញ្ជីមរណភាព

អ្នករាយការណ៍ ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីមរណភាពនៅការិយាល័យអត្រានុកូលដ្ឋានណាមួយនេះ៖

ក- ឃុំ សង្កាត់ដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង។

ខ- ឃុំ សង្កាត់ដែលមរណជនស្នាក់នៅ។

គ- កន្លែងផ្សេងទៀត តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

### មាត្រា៤៣.- រយៈពេលចុះបញ្ជីមរណភាព

អ្នករាយការណ៍ ត្រូវដាក់ពាក្យចុះបញ្ជីមរណភាពក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង។

### មាត្រា៤៤.- អ្នករាយការណ៍អំពីមរណភាព

១- បុគ្គលដែលទទួលខុសត្រូវជាអ្នករាយការណ៍អំពីមរណភាព ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

ក- សម្រាប់មរណភាពរបស់អនីតិជន៖

- ម្តាយឬឪពុកឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន
- ញាតិជានីតិជនរបស់មរណជន
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់នេះឬច្បាប់ផ្សេងទៀត។

ខ- សម្រាប់មរណភាពរបស់នីតិជន៖

- សហព័ទ្ធរបស់មរណជន
- ញាតិជានីតិជនរបស់មរណជន
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់នេះឬច្បាប់ផ្សេងទៀត។

គ- សម្រាប់មរណភាពដោយសារមូលហេតុខុសប្រក្រតី ឬគួរឱ្យសង្ស័យ ឬបណ្តាលពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ ត្រូវរាយការណ៍ដោយបុគ្គលឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធតាមការកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នេះ។

២- ប្រសិនបើអ្នករាយការណ៍ជាអនីតិជនឬជននៅក្រោមអាណាព្យាបាលទូទៅ ទម្រង់បែបបទនិងនីតិវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា៤៥.- ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល

១- ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលមរណភាពបានកើតឡើងត្រូវផ្តល់ឯកសារបញ្ជាក់អំពីមរណភាពមួយច្បាប់ទៅឱ្យអ្នករាយការណ៍ទៅតាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា៤៤(អ្នករាយការណ៍អំពីមរណភាព) នៃច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២- ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្តល់ឯកសារបញ្ជាក់អំពីមរណភាពឱ្យអ្នករាយការណ៍ ប្រសិនបើមរណភាពរបស់ជននោះកើតឡើងមុនពេលទៅដល់មូលដ្ឋានសុខាភិបាល ហើយបានធ្វើដំណើរទៅដល់មូលដ្ឋានសុខាភិបាល។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារបញ្ជាក់អំពីមរណភាពនោះមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៤- ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីមរណភាពដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤៦.- ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល**

១- ប្រសិនបើមរណភាពកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល អ្នករាយការណ៍ត្រូវរាយការណ៍អំពីមរណភាពទៅអាជ្ញាធរមានសមត្ថកិច្ច។ អាជ្ញាធរមានសមត្ថកិច្ចត្រូវសហការជាមួយមូលដ្ឋានសុខាភិបាលធ្វើការត្រួតពិនិត្យ ដើម្បីឱ្យមូលដ្ឋានសុខាភិបាលបញ្ជាក់អំពីមរណភាពនិងផ្តល់ឯកសារបញ្ជាក់អំពីមរណភាពទៅឱ្យអ្នករាយការណ៍។

២- មូលដ្ឋានសុខាភិបាលត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារបញ្ជាក់អំពីមរណភាព១(មួយ) ច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៣- ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីមរណភាពដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤៧.- ការជូនដំណឹងអំពីមរណភាពបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ**

១- ក្នុងករណីដែលមាត្រា៤៥(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល) និងមាត្រា៤៦(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល) នៃច្បាប់នេះ មិនអាចអនុវត្តបានចំពោះមរណភាពបន្សល់ទុកសាកសពដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ នីតិវិធីសម្រាប់ជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអំពីមរណភាពដែលកើតឡើងដោយសារគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ ត្រូវកំណត់ដោយអនុក្រឹត្យ។

២- គ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវប្រកាសដោយរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤៨.- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពក្នុងករណីមរណភាពប្រក្រតី**

១- នៅពេលដែលមរណភាពរបស់ជនណាម្នាក់កើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាលឬនៅពេលដែលជននោះកំពុងធ្វើដំណើរទៅមូលដ្ឋានសុខាភិបាល ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវកំណត់មូលហេតុនៃមរណភាព បើអាចធ្វើទៅបាន។

២- នៅពេលដែលមរណភាពរបស់ជនណាម្នាក់កើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវកំណត់អំពីមូលហេតុនៃមរណភាព ប្រសិនបើអាច។

៣- ទម្រង់ បែបបទ និងនីតិវិធីនៃការកំណត់អំពីមូលហេតុនៃមរណភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

៤- ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវជានាបញ្ជូនព័ត៌មានអំពីមូលហេតុនៃមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។ នីតិវិធីបញ្ជូនព័ត៌មានត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤៩.- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពខុសប្រក្រតីឬគួរឱ្យសង្ស័យ**

១- ប្រធានមូលដ្ឋានសុខាភិបាល អ្នកប្រកបអាជីពវេជ្ជសាស្ត្រ មន្ត្រីអត្រានុកូលដ្ឋានឬបុគ្គលដែលពាក់ព័ន្ធដែលមានការសង្ស័យថាមរណភាពមួយបង្កឡើងដោយមូលហេតុមិនប្រក្រតី ត្រូវរាយការណ៍ករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត។

២- ក្រោយពេលបញ្ចប់ការស៊ើបអង្កេតពាក់ព័ន្ធនឹងមូលហេតុនៃមរណភាព អាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់អំពីមូលហេតុនៃមរណភាពទៅតាមទម្រង់ដែលកំណត់ដោយក្រសួងសុខាភិបាល។

៣- អាជ្ញាធរមានសមត្ថកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវជានាថាព័ត៌មានអំពីមូលហេតុនៃមរណភាពត្រូវបានបញ្ជូនទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៤- នីតិវិធីនៃការបញ្ជូនព័ត៌មានដូចបានកំណត់នៅក្នុងកថាខណ្ឌទី៣ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៥០.- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ**

ក្នុងករណីដែលមាត្រា៤៨(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតី) និងមាត្រា៤៩(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពខុសប្រក្រតីឬគួរឱ្យសង្ស័យ) នៃច្បាប់នេះ មិនអាចអនុវត្តបានដោយសារតែមរណភាពដែលបណ្ដាលមកពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ នីតិវិធីសម្រាប់ផ្ដល់លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៥១ .- ការកំណត់មូលហេតុនៃមរណភាពដោយការសាកសួរផ្ទាល់មាត់**

១- ក្នុងករណីដែលមូលហេតុនៃមរណភាពមិនអាចកំណត់បានតាមបញ្ញត្តិនៃមាត្រា៤៨ (លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតី) មូលហេតុនៃមរណភាព អាចត្រូវបានកំណត់ដោយនីតិវិធីនៃការសាកសួរផ្ទាល់មាត់។

២- នីតិវិធីនៃការសាកសួរផ្ទាល់មាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៥២ .- ពាក្យសុំចុះបញ្ជីមរណភាព**

១- អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីមរណភាពជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។

២- ក្នុងពាក្យសុំចុះបញ្ជីមរណភាព អ្នករាយការណ៍ត្រូវបំពេញនូវចំណុចខាងក្រោមនេះ៖

ក- ឈ្មោះរបស់មរណជន។

ខ- ភេទរបស់មរណជន។

គ- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន។

ឃ- ថ្ងៃ ខែ ឆ្នាំ ម៉ោងនិងទីកន្លែងដែលមរណជនទទួលមរណភាព។

ង- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍ ព្រមទាំងទំនាក់ទំនងរវាងអ្នករាយការណ៍និងមរណជន។

ច- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។

ឆ- ចំណុចផ្សេងទៀតតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ទម្រង់និងបែបបទនៃពាក្យសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៥៣ .- ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព**

១- អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីមរណភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២នៃមាត្រា៤៥(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល) ឬមាត្រា៤៦(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល) ឬមាត្រា៤៧(ការជូនដំណឹងអំពីមរណភាពបណ្ដាលមកពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ) នៃច្បាប់នេះ ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព។

២- អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណបុគ្គលរបស់មរណជនជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព។

**មាត្រា៥៤ .- នីតិវិធីចុះបញ្ជីមរណភាព**

១- នៅពេលទទួលបានពាក្យសុំចុះបញ្ជីមរណភាពនិងឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា៥២(ពាក្យសុំចុះបញ្ជីមរណភាព) និងមាត្រា៥៣(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងកត់ត្រាព័ត៌មាននោះទៅក្នុងបញ្ជីមរណភាព។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីមរណភាព រួមមានឈ្មោះ ភេទ ថ្ងៃខែឆ្នាំ និងទីកន្លែងដែលមរណជនទទួលមរណភាព។

៣- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីមរណភាពខ្វះនូវព័ត៌មានណាមួយក្នុងចំណោមព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានដែលខ្វះនោះ ដោយកំណត់រយៈពេលសមរម្យ។

៤- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចមិនត្រូវបដិសេធចុះបញ្ជីមរណភាពដោយសារខ្វះលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពឡើយ។

៥- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីមរណភាពខ្វះនូវព័ត៌មានមួយចំនួនក្នុងចំណោមចំណុចនីមួយៗដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា៥២(ពាក្យសុំចុះបញ្ជីមរណភាព) នៃច្បាប់នេះ ក្រៅពីព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ឬខ្វះឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា៥៣(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីមរណភាពតាមព័ត៌មានដែលមាននោះ។ ក្នុងករណីនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានបន្ថែមដោយកំណត់រយៈពេលសមរម្យ។

៦- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី៣ខាងលើនេះក៏ដោយ មន្ត្រីអត្រានុកូលដ្ឋានអាចចុះបញ្ជីដោយឆន្ទានុសិទ្ធិឬដោយទទួលការអនុញ្ញាតពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានទទួលព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះតាមការជូនដំណឹងពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឬវិធីផ្សេងទៀត។

**មាត្រា៥៥.- សំបុត្រមរណភាព**

១- ក្រោយពេលចុះបញ្ជីមរណភាពរួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រមរណភាពច្បាប់ដើម១(មួយ)ច្បាប់ជូនអ្នករាយការណ៍ដោយឥតគិតថ្លៃ។

២- ព័ត៌មាននៅលើសំបុត្រមរណភាពច្បាប់ដើម រួមមាន៖

ក- ឈ្មោះរបស់មរណជន។

ខ- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន។

គ- ភេទរបស់មរណជន។

ឃ- ទីកន្លែងនិងកាលបរិច្ឆេទនៃមរណភាពរបស់មរណជន។

ង- ព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៥៦.- សេចក្តីចម្លងសំបុត្រមរណភាពនិងសម្រង់បញ្ជីមរណភាព**

១- បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រមរណភាពនិងសម្រង់បញ្ជីមរណភាពបានរួមមាន៖

ក- ញាតិនៃមរណជន។

ខ- អ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកតំណាងដោយអាណត្តិរបស់ញាតិនៃមរណជន។

គ- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលស្នើសុំសេចក្តីចម្លងសំបុត្រមរណភាព និងសម្រង់បញ្ជីមរណភាពមិនមែនជាបុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើឬការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវ ដូចជាគោលបំណងធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ញាតិនៃមរណជន មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះនិងត្រូវផ្តល់មូលហេតុសម្រាប់ការបដិសេធនោះ។ ការបដិសេធនេះអាចប្តឹងមិនសុខចិត្តបាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី១៣(បណ្តឹងមិនសុខចិត្ត) នៃជំពូកនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្តីចម្លងសំបុត្រមរណភាពឬសម្រង់បញ្ជីមរណភាព ក្នុងករណីដែលមានការចាំបាច់ ដើម្បីបំពេញកិច្ចការរបស់ខ្លួន ដោយផ្អែកលើច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។

**មាត្រា៥៧.- ទម្រង់សំបុត្រមរណភាពនិងសេចក្តីចម្លងសំបុត្រមរណភាព**

១- សំបុត្រមរណភាពនិងសេចក្តីចម្លងសំបុត្រមរណភាព ត្រូវមានលក្ខណៈសម្គាល់ធានាសុវត្ថិភាព ដើម្បីការពារការក្លែងបន្លំ។

២- ទម្រង់សំបុត្រមរណភាពនិងសេចក្តីចម្លងសំបុត្រមរណភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៥៨.- ការបិទអត្តសញ្ញាណខាងផ្លូវច្បាប់របស់មរណជន**

១- ក្រោយពេលចុះបញ្ជីមរណភាព មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវធានាឱ្យមានការផ្ទៀងផ្ទាត់រវាងបញ្ជីមរណភាពទៅនឹងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជនដើម្បីចុះនិទ្ទេសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតនោះថាបុគ្គលនោះបានទទួលមរណភាព។ ក្រោយពេលចុះនិទ្ទេសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរួចហើយ ប្រសិនបើមានការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជន សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានផ្សេងទៀតនោះត្រូវសរសេរបញ្ជាក់ថាស្លាប់។

២- បែបបទនិងនីតិវិធីនៃការផ្ទៀងផ្ទាត់រវាងបញ្ជីមរណភាពទៅនឹងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវផ្តល់ព័ត៌មានជូនមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។ មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ត្រូវបិទលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់មរណជន ដូចមានចែងនៅក្នុងជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ។

**មាត្រា៥៩.- នីតិវិធីសម្រាប់ចុះបញ្ជីមរណភាពជនបរទេស**

មរណភាពរបស់ជនបរទេសដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីដោយយោងទៅតាមនីតិវិធីដូចមានចែងនៅក្នុងផ្នែកទី៦(ការចុះបញ្ជីមរណភាព) នៃជំពូកនេះ។ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់សំបុត្រមរណភាពឱ្យបានឆាប់តាមតែអាចធ្វើទៅបាន ដើម្បីសម្រួលដល់ការដឹកជញ្ជូនឆ្លងប្រទេសនិងការបូជាឬការបញ្ចុះសព។

**មាត្រា៦០.- ការចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណ**

១- ក្នុងករណីដែលសពដែលមិនស្គាល់អត្តសញ្ញាណ អ្នកដែលបានឃើញសាកសពនោះត្រូវផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត។

២- អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ព័ត៌មាននិងឯកសារទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចដើម្បីជាមូលដ្ឋានសម្រាប់ចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណនោះ ដូចខាងក្រោម៖

- ក- ព័ត៌មានអំពីមរណភាពឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានតាមឯកសារបញ្ជាក់អំពីមរណភាពដែលត្រូវបានកំណត់តាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។
- ខ- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុមរណភាពមួយច្បាប់ ប្រសិនបើមាន។
- គ- លេខកំណត់ហេតុស៊ើបអង្កេត។
- ឃ- ព័ត៌មានផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ទោះបីជាខ្វះព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២នៃមាត្រា៥៤(នីតិវិធីចុះបញ្ជីមរណភាព) នៃច្បាប់នេះក៏ដោយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីអំពីមរណភាពនោះ។

**មាត្រា៦១.- ការចុះបញ្ជីបុគ្គលដែលត្រូវបានចាត់ទុកថាបានទទួលមរណភាព**

១- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវចុះបញ្ជីមរណភាពឱ្យបុគ្គលដែលចាត់ទុកថាបានទទួលមរណភាព ក្រោយពេលទទួលបានការប្រកាសរបស់តុលាការអំពីការបាត់ខ្លួនស្របតាមមាត្រា៤១(លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) មាត្រា៤២(ការដាស់តឿនជាសាធារណៈ) និងមាត្រា៤៣(អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) នៃក្រមរដ្ឋប្បវេណី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវធ្វើមោឃភាពបញ្ជីមរណភាពក្រោយពេលទទួលបានសេចក្តីសម្រេចរបស់តុលាការស្តីពីការលុបចោលការប្រកាសអំពីការបាត់ខ្លួន ស្របតាមមាត្រា៤៤ (ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រលប់មកវិញ) នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីនេះ បញ្ជីមរណភាពដែលបានចុះដោយយោងតាមកថាខណ្ឌទី១ខាងលើនេះ ត្រូវរក្សាទុកស្របតាមផ្នែកទី១១ (ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន ការថែទាំ ការរក្សាទុក ការបញ្ជូនបញ្ជី ព័ត៌មាន និងរបាយការណ៍ស្តីពីការងារអត្រានុកូលដ្ឋាន) នៃជំពូកនេះ។

## មាត្រា៦២.- ការរាយការណ៍អំពីមរណភាពដែលបានកើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា

១- ប្រសិនបើប្រជាពលរដ្ឋខ្មែរណាម្នាក់ ទោះបីបានទទួលឬមិនបានទទួលលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលក្រោមច្បាប់នេះឬបុគ្គលមិនមែនជាប្រជាពលរដ្ឋខ្មែរដែលបានទទួលលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលក្រោមច្បាប់នេះ បានទទួលមរណភាពនៅក្រៅព្រះរាជាណាចក្រកម្ពុជា៖

ក- អ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពនេះទៅមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចនៅប្រទេសដែលមរណភាពបានកើតឡើង ដោយផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម៖
- សំបុត្រមរណភាពឬភស្តុតាងអំពីមរណភាពផ្សេងទៀតពីប្រទេសដែលមរណភាពបានកើតឡើង
- ឯកសារភ្ជាប់ផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

ខ- ប្រសិនបើគ្មានស្ថានតំណាងឬពុំអាចរាយការណ៍ឬពុំមានលទ្ធភាពរាយការណ៍អំពីមរណភាពនេះជូនស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចនោះ អ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពជូនមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ក្រោយពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ដោយផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម៖
- សំបុត្រមរណភាពឬភស្តុតាងអំពីមរណភាពផ្សេងទៀតពីប្រទេសដែលមរណភាពបានកើតឡើង
- ឯកសារភ្ជាប់ផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

២- ក្នុងករណីដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្ទៀតផ្ទាត់និងកត់ត្រាព័ត៌មានទាក់ទងនឹងព្រឹត្តិការណ៍មរណភាព ដូចមានក្នុងសំបុត្រមរណភាពឬភស្តុតាងបញ្ជាក់អំពីមរណភាពផ្សេងទៀតពីប្រទេសដែលព្រឹត្តិការណ៍មរណភាពនោះបានកើតឡើងនិងចេញសំបុត្រមរណភាព ដោយអនុលោមតាមមាត្រា៥៥(សំបុត្រមរណភាព) នៃច្បាប់នេះ។

**មាត្រា៦៣.- ការអនុញ្ញាតឱ្យបូជាឬបញ្ចុះសព**

១- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសព។ គ្មានសពណាអាចត្រូវបានបូជាឬបញ្ចុះ ដោយគ្មានលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសព ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចឡើយ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់នេះឬច្បាប់ផ្សេង។

២- ក្រោយពីមន្ត្រីអត្រានុកូលដ្ឋានបានទទួលពាក្យសុំចុះបញ្ជីមរណភាព ដែលបានកំណត់នៅក្នុងមាត្រា៥២(ពាក្យសុំចុះបញ្ជីមរណភាព) ដោយភ្ជាប់ជាមួយឯកសារដែលបានកំណត់នៅក្នុងមាត្រា៥៣(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសព។

៣- ទោះបីជាមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី២ខាងលើនេះក៏ដោយ មន្ត្រីអត្រានុកូលដ្ឋានដែលមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសពជាបន្ទាន់នៅពេលទទួលបានព័ត៌មាន និងការបញ្ជាក់អំពីភាពចាំបាច់ក្នុងការបូជាឬបញ្ចុះសពពីអាជ្ញាធរមានសមត្ថកិច្ច។

៤- ប្រសិនបើលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសពជាបន្ទាន់មួយត្រូវបានចេញស្របតាមកថាខណ្ឌទី៣ខាងលើ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើការតាមដានបន្តជាមួយគ្រួសារនៃមរណជន ដើម្បីធានាថាមានអ្នករាយការណ៍សមស្របបានដាក់ពាក្យសុំចុះបញ្ជីមរណភាព ស្របតាមមាត្រា៥២(ពាក្យសុំចុះបញ្ជីមរណភាព) មាត្រា៥៣(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព) និងមាត្រា៥៤(នីតិវិធីចុះបញ្ជីមរណភាព) នៃច្បាប់នេះ។

៥- បុគ្គលដែលទទួលខុសត្រូវនៃទីកន្លែងដែលបូជាឬបញ្ចុះសព ត្រូវឱ្យបុគ្គលដែលស្នើសុំឱ្យបូជាឬបញ្ចុះសពបង្ហាញលិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសព។

**មាត្រា៦៤.- ការចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះមួយឆ្នាំ**

១- ប្រសិនបើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង អ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពនោះបានកើតឡើង។ អ្នករាយការណ៍ក៏ត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលមរណភាពបានកើតឡើង។

២- នៅពេលមន្ត្រីអត្រានុកូលដ្ឋានបានទទួលពាក្យសុំចុះបញ្ជី ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីមរណភាពដោយអនុលោមតាមមាត្រា៥៤(នីតិវិធីចុះបញ្ជីមរណភាព) នៃច្បាប់នេះ។ មន្ត្រីអត្រានុកូលដ្ឋានមិនអាចបដិសេធពាក្យសុំចុះបញ្ជីមរណភាពដោយផ្អែកលើមូលហេតុនៃការពន្យល់អំពីការយឺតយ៉ាវក្នុងការដាក់ពាក្យសុំចុះបញ្ជីនោះឡើយ។

## មាត្រា៦៥.- ការចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ

១- ប្រសិនបើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ ក្រៅពីឯកសារភ្ជាប់ដូចមានចែងនៅក្នុងមាត្រា៥៣(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព) នៃច្បាប់នេះ អ្នករាយការណ៍ត្រូវផ្តល់ព័ត៌មានឬឯកសារបន្ថែមដូចខាងក្រោម៖

- ការធានាអះអាងនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរបស់សាក្សីនៃមរណភាពនេះ
- ឯកសារឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់អំពីព្រឹត្តិការណ៍នៃមរណភាព ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

២- អ្នករាយការណ៍ក៏ត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេលអនុគ្រោះ១(មួយ)ឆ្នាំ។

៣- នៅពេលទទួលបានព័ត៌មាននិងឯកសារដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីមរណភាពនោះ។ មន្ត្រីអត្រានុកូលដ្ឋានមិនអាចបដិសេធពាក្យសុំចុះបញ្ជីមរណភាពដោយសារផុតរយៈពេលអនុគ្រោះឡើយ។

## មាត្រា៦៦.- ការដាស់តឿននិងការចុះបញ្ជីមរណភាពចល័តតាមមូលដ្ឋាន

១- នៅពេលមន្ត្រីអត្រានុកូលដ្ឋានដឹងថាមានព្រឹត្តិការណ៍មរណភាពមួយបានកើតឡើងតាមរយៈការជូនដំណឹងពីអាជ្ញាធរពាក់ព័ន្ធឬប្រភពផ្សេងទៀត ហើយអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេលដូចមានកំណត់នៅក្នុងមាត្រា៤៣(រយៈពេលចុះបញ្ជីមរណភាព) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវដាស់តឿនដល់អ្នករាយការណ៍ឱ្យដាក់ពាក្យសុំចុះបញ្ជីដោយកំណត់រយៈពេលសមស្រប។

២- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ អាចចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីចុះបញ្ជីមរណភាពដែលមិនទាន់បានចុះបញ្ជីកន្លងមកដោយអនុលោមតាមបញ្ញត្តិនៃផ្នែកទី៦(ការចុះបញ្ជីមរណភាព) នៃជំពូកនេះ។

# ផ្នែកទី៧
# ការចុះបញ្ជីអាពាហ៍ពិពាហ៍

## មាត្រា៦៧.- ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

បុរសម្នាក់និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបុរសឬនារីនោះរស់នៅ។

## មាត្រា៦៨.- ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

១- បុរសម្នាក់និងនារីម្នាក់ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានដូចមានកំណត់នៅក្នុងមាត្រា៦៧(ទីកន្លែងដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍) នៃច្បាប់នេះ។ ទម្រង់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រូវភ្ជាប់នូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ប្រសិនបើបុរសឬនារីមិនទាន់ដល់នីតិភាព ប៉ុន្តែមានអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ដោយអនុលោមតាមមាត្រា៩៤៨(អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី អ្នកមានអំណាចមេបាឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់បុរសឬនារីនោះ ត្រូវផ្តល់ការយល់ព្រមនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឬជាលាយលក្ខណ៍អក្សរ។

៤- មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ពាក្យសុំនិងឯកសារភ្ជាប់ដោយអនុលោមតាមមាត្រា៩៥៦(ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី។

**មាត្រា៦៩.- ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍**

១- មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្សព្វផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ តាមរយៈការបិទបណ្ណប្រកាស១(មួយ)ច្បាប់នៅលំនៅឋានរបស់នារីនិង១(មួយ)ច្បាប់ទៀតនៅសាលាឃុំ សង្កាត់នៃលំនៅឋានរបស់នារីនិងត្រូវបញ្ជូនបណ្ណប្រកាសចំនួន២(ពីរ)ច្បាប់ទៀតទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបុរសរស់នៅ ដើម្បីបិទបណ្ណប្រកាសនោះ១(មួយ)ច្បាប់នៅលំនៅឋានរបស់បុរសនិង១(មួយ)ច្បាប់ទៀត នៅសាលាឃុំ សង្កាត់នៃលំនៅឋានរបស់បុរស។

២- ទម្រង់និងព័ត៌មាននៃបណ្ណប្រកាសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់ក្នុងរយៈពេល១០(ដប់)ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេល១០(ដប់)ថ្ងៃនោះ។ ប្រសិនបើគ្មានការជំទាស់នៅក្នុងរយៈពេល១០(ដប់)ថ្ងៃនោះទេ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលា នៅក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

៤- ប្រសិនបើបុរសនិងនារីដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ មិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរសនិងនារីនោះបាន។

**មាត្រា៧០.- ការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន**

១- អាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរសនិងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។

២- ព័ត៌មានឬចំណុចដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបញ្ចូលទៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននិងចុះហត្ថលេខាឬផ្តិតស្នាមមេដៃដោយបុគ្គលដែលមានបំណងធ្វើជាសហព័ទ្ធនិងដោយមានសាក្សីចំនួន២(ពីរ)រូបជានីតិជន។

**មាត្រា៧១.- ការផ្ដល់សំបុត្រអាពាហ៍ពិពាហ៍**

ក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍រួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម១(មួយ)ច្បាប់ជូនប្ដីប្រពន្ធនោះដោយឥតគិតថ្លៃ។

**មាត្រា៧២.- ការចេញសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍និងសម្រង់បញ្ជីអាពាហ៍ពិពាហ៍**

១- បុគ្គលដែលអាចស្នើសុំសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍បាន រួមមាន៖

ក- សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។

ខ- ញាតិលោហិតផ្ទាល់នៃសាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។

គ- អ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ ដូចមានចែងនៅក្នុងចំណុច ក និងខ។

ឃ- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលស្នើសុំសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍មិនមែនជាបុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើឬការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវ ដូចជាគោលបំណងធ្វើឱ្យមានការប៉ះពាល់ភាពឯកជនរបស់សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះនិងត្រូវផ្ដល់មូលហេតុសម្រាប់ការបដិសេធនោះ។ ការបដិសេធនេះអាចប្ដឹងមិនសុខចិត្តបាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី១៣(បណ្ដឹងមិនសុខចិត្ត) នៃជំពូកនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ឬសម្រង់បញ្ជីអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានការចាំបាច់ដើម្បីបំពេញកិច្ចការរបស់ខ្លួនដោយផ្អែកលើច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្ដល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។

**មាត្រា៧៣.- ទម្រង់សំបុត្រអាពាហ៍ពិពាហ៍និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍**

១- សំបុត្រអាពាហ៍ពិពាហ៍និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវមានលក្ខណៈសម្គាល់ជានាសុវត្ថិភាព ដើម្បីការពារការក្លែងបន្លំ។

២- ទម្រង់សំបុត្រអាពាហ៍ពិពាហ៍និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៧៤.- ការចុះបញ្ជីអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរនៅបរទេស**

សំណើសុំរៀបអាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរនិងប្រជាពលរដ្ឋខ្មែរ ឬរវាងប្រជាពលរដ្ឋខ្មែរនិងជនបរទេសដែលរស់នៅស្របច្បាប់នៅបរទេស អាចធ្វើឡើងចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន

ប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចនៅប្រទេសដែលសាមីជនរស់នៅស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងមាត្រា៦៩(ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍) នៃច្បាប់នេះ ត្រូវធ្វើតែនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចនៅប្រទេសដែលសាមីជននោះរស់នៅតែប៉ុណ្ណោះ។

**មាត្រា៧៥.- ការទទួលស្គាល់អាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរនៅបរទេស**

១- អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរនិងប្រជាពលរដ្ឋខ្មែរឬរវាងប្រជាពលរដ្ឋខ្មែរនិងជនបរទេស ដែលត្រូវបានធ្វើឡើងស្របតាមទម្រង់ដែលបានកំណត់ក្នុងច្បាប់បរទេសដែលអនុវត្តនៅទីកន្លែងដែលអាពាហ៍ពិពាហ៍បានធ្វើឡើងត្រូវបានទទួលស្គាល់ឱ្យចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយពីបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ការចុះបញ្ជីអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ អាចចុះនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចនៅប្រទេសដែលអាពាហ៍ពិពាហ៍បានធ្វើឡើងឬចុះបញ្ជីនៅឃុំ សង្កាត់ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ប្ដីប្រពន្ធនោះ តាមរយៈការបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ពីប្រទេសនោះនិងព័ត៌មានចាំបាច់ផ្សេងទៀតតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍រួច មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចឬមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម១(មួយ)ច្បាប់ឱ្យទៅប្ដីប្រពន្ធនោះ។

**មាត្រា៧៦.- អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរនិងជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

១- អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរនិងជនបរទេសដែលចូលឬស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ប្រសិនបើជនបរទេសគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងមាត្រា៦៩(ការជូនដំណឹងជាសាធារណៈអំពីការរៀបចំអាពាហ៍ពិពាហ៍) នៃច្បាប់នេះ ត្រូវធ្វើតាមរយៈការបិទបណ្ណប្រកាស១(មួយ)ច្បាប់នៅលំនៅឋានរបស់ប្រជាពលរដ្ឋខ្មែរនិង១(មួយ)ច្បាប់ទៀតនៅសាលាឃុំ សង្កាត់នៃលំនៅឋានរបស់ប្រជាពលរដ្ឋខ្មែរ។

៣- ទម្រង់ បែបបទ និងនីតិវិធីសម្រាប់អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរនិងជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៧.- អាពាហ៍ពិពាហ៍រវាងជនបរទេសនិងជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

១- ជនបរទេសដែលចូលឬស្នាក់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា អាចសុំរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសផ្សេងទៀតដែលចូលឬស្នាក់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ប្រសិនបើជនបរទេសនិងជនបរទេសរៀបអាពាហ៍ពិពាហ៍ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ការចុះឈ្មោះជនបរទេសត្រូវសរសេរជាភាសាខ្មែរ អមជាមួយអក្សរឡាតាំង។

## ផ្នែកទី៨
## ការចុះបញ្ជីអំពីការលែងលះ មោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍

### មាត្រា៧៨.- ការចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

១- ក្នុងករណីដែលសេចក្តីសម្រេចអំពីការលែងលះ មោឃភាពឬការលុបចោលអាពាហ៍ពិពាហ៍បានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ដែលអ្នកដាក់ពាក្យសុំទៅតុលាការរស់នៅ ដោយភ្ជាប់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចរបស់តុលាការនោះនិងសេចក្តីបញ្ជាក់អំពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ។

២- ក្នុងករណីដែលសេចក្តីសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្តដែលចេញសេចក្តីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។

៣- ក្នុងករណីដែលសេចក្តីសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាឧទ្ធរណ៍ឬតុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ឬអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដែលចេញសេចក្តីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

### មាត្រា៧៩.- នីតិវិធីចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

ក្រោយពេលទទួលបាននូវការរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ឬការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ឬកថាខណ្ឌទី៣នៃមាត្រា៧៨(ការចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មាននោះទៅនឹងបញ្ជីអាពាហ៍ពិពាហ៍របស់សាមីជនទាំង២(ពីរ)នាក់និងត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីអាពាហ៍ពិពាហ៍នោះ។

### មាត្រា៨០.- ការទទួលស្គាល់និងការចុះបញ្ជីការលែងលះនៅបរទេស

ប្រសិនបើប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការលែងលះនៅក្រៅព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់នៃប្រទេសនោះ ការលែងលះនេះត្រូវបានទទួលស្គាល់យកជាការបានក្នុងព្រះរាជាណាចក្រកម្ពុជា។ បុគ្គលដែលបានលែងលះនោះ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ត្រូវផ្តល់សេចក្តីសម្រេចឬលិខិតបញ្ជាក់អំពីការលែងលះរបស់ស្ថាប័នមានសមត្ថកិច្ចនៅក្រៅប្រទេសនោះទៅឱ្យមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានទៅនឹងបញ្ជីអាពាហ៍ពិពាហ៍របស់សាមីជនទាំង២(ពីរ)នាក់និងត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីអាពាហ៍ពិពាហ៍នោះ។

## ផ្នែកទី៩
## ការចុះបញ្ជីអត្រានុកូលដ្ឋានផ្សេងៗ

### មាត្រា៨១ .- ការចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ

១- ក្នុងករណីដែលសេចក្តីសម្រេចរបស់តុលាការដូចបានកំណត់ខាងក្រោមនេះបានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបានចុះបញ្ជីកំណើតរស់របស់កូន ឬឃុំ សង្កាត់នៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំ ឬឃុំ សង្កាត់ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចរបស់តុលាការនោះនិងសេចក្តីបញ្ជាក់អំពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរៈ

- ក- ការបដិសេធបិតុភាព ដែលបានកំណត់នៅក្នុងមាត្រា៩៨៩(ការបដិសេធបិតុភាព) នៃក្រមរដ្ឋប្បវេណី។
- ខ- ការទទួលស្គាល់ ដែលបានកំណត់នៅក្នុងមាត្រា១០០១(បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី។
- គ- ការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ដែលបានកំណត់នៅក្នុងមាត្រា១០០២(បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី។
- ឃ- ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ដែលបានកំណត់នៅក្នុងមាត្រា១០០៤(បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) ឬមាត្រា១០០៥(បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្តាយ)នៃក្រមរដ្ឋប្បវេណី។
- ង- សុំកូនពេញលេញ ដែលបានកំណត់នៅក្នុងមាត្រា១០០៧(ទម្រង់នៃការបង្កើតសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី។
- ច- ការកាត់កាល់សុំកូនពេញលេញ ដែលបានកំណត់នៅក្នុងមាត្រា១០១៦(ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី។
- ឆ- សុំកូនធម្មតា ដែលបានកំណត់នៅក្នុងមាត្រា១០២០(ពាក្យសុំនៃសុំកូនធម្មតា) នៃក្រមរដ្ឋប្បវេណី។
- ជ- ការកាត់កាល់សុំកូនធម្មតា ដែលបានកំណត់នៅក្នុងមាត្រា១០២៨(ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមរដ្ឋប្បវេណី។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ក្នុងករណីដែលសេចក្តីសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត ដែលចេញសេចក្តីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។

៣- ក្នុងករណីដែលសេចក្តីសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាឧទ្ធរណ៍ឬតុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ឬអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដែលចេញសេចក្តីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៤- ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានទទួលការរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីឬកែតម្រូវបញ្ជីតាមការរាយការណ៍នោះ ហើយដកហូតសំបុត្រកំណើតចាស់និងចេញសំបុត្រកំណើតថ្មី។

៥- ទម្រង់ បែបបទ និងនីតិវិធីនៃការចុះបញ្ជីចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៦- បញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤០(ការដាស់តឿននិងការចុះបញ្ជីកំណើតរស់ចល័តតាមមូលដ្ឋាន) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការចុះបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា៨២.- ការចុះបញ្ជីពាក់ព័ន្ធនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត**

១- ក្នុងករណីដែលឪពុកទទួលស្គាល់កូនដោយស្ម័គ្រចិត្ត ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៩៩៣(ការទទួលស្គាល់ដោយស្ម័គ្រចិត្ត) នៃក្រមរដ្ឋប្បវេណី ឪពុកនោះត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបានចុះបញ្ជីកំណើតរស់របស់កូននោះ។

២- ក្នុងករណីដែលឪពុកទទួលស្គាល់ទារកនៅក្នុងគភ៌ ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៩៩៥(ការទទួលស្គាល់របស់ឪពុក) នៃក្រមរដ្ឋប្បវេណី ឪពុកនោះត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ម្តាយរបស់ទារកនោះដោយទទួលការយល់ព្រមពីម្តាយ។ ក្នុងករណីនេះ ប្រសិនបើទារកនៅក្នុងគភ៌ដែលត្រូវបានទទួលស្គាល់ដោយឪពុកបាត់បង់ជីវិតមុនពេលកើត ម្តាយឬឪពុករបស់ទារកនោះ ក្រៅពីការកត់ត្រាព័ត៌មានអំពីទារកស្លាប់កើត ត្រូវជូនដំណឹងអំពីព្រឹត្តិការណ៍នោះទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលឪពុកបានរាយការណ៍អំពីការទទួលស្គាល់។

៣- បញ្ញត្តិនៃកថាខណ្ឌទី៤ នៃមាត្រា៨១(ការចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ) នៃច្បាប់នេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ។

៤- ក្នុងករណីដែលឪពុកទទួលស្គាល់កូនដែលបានទទួលមរណភាព ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា៩៩៦(ការទទួលស្គាល់កូនជានីតិជននិងកូនដែលបានទទួល

មរណភាព) នៃក្រមរដ្ឋប្បវេណី ឪពុកនោះត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបានចុះបញ្ជីកំណើតរបស់កូន ដោយបញ្ជាក់អំពីថ្ងៃ ខែ ឆ្នាំដែលកូននោះបានទទួលមរណភាព និងបច្ចាញាតិផ្ទាល់របស់កូននោះ។

៥- ក្នុងករណីដែលឪពុកទទួលស្គាល់កូនតាមមតកសាសន៍ ដោយអនុលោមតាមបញ្ញត្តិនៃវាក្យខណ្ឌទី២នៃកថាខណ្ឌទី១នៃមាត្រា៩៩៧(ទម្រង់នៃការទទួលស្គាល់)នៃក្រមរដ្ឋប្បវេណី អ្នកប្រតិបត្តិមតកសាសន៍ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបានចុះបញ្ជីកំណើតរបស់កូន ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃមតកសាសន៍នោះ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលអ្នកប្រតិបត្តិមតកសាសន៍នោះកាន់មុខងាររបស់ខ្លួន។

៦- ទម្រង់ បែបបទ និងនីតិវិធីនៃការចុះបញ្ជីចំពោះករណីដែលបានកំណត់ពីកថាខណ្ឌទី១ ដល់កថាខណ្ឌទី៥ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា៨៣ .- ការចុះបញ្ជីរលត់ទំនាក់ទំនងញាតិពន្ធដោយសារមរណភាពរបស់សហព័ទ្ធ

១- ក្នុងករណីដែលសហព័ទ្ធម្ខាងបានទទួលមរណភាព ហើយប្រសិនបើសហព័ទ្ធដែលនៅរស់មានបំណងបញ្ចប់ទំនាក់ទំនងញាតិពន្ធដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) នៃក្រមរដ្ឋប្បវេណី សហព័ទ្ធដែលនៅរស់នោះត្រូវបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានរបស់សហព័ទ្ធដែលនៅរស់នោះ។ បញ្ញត្តិនេះមិនរារាំងសហព័ទ្ធដែលនៅរស់ក្នុងការបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដែលខ្លួនរាយការណ៍អំពីមរណភាពរបស់សហព័ទ្ធនោះឡើយ។

២- ក្នុងករណីដែលមានការបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានដែលមានសមត្ថកិច្ចត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីអាពាហ៍ពិពាហ៍របស់សហព័ទ្ធនៅរស់និងមរណភាពនោះ។

### មាត្រា៨៤ .- ការចុះបញ្ជីផ្ដាច់មត៌ក

១- ក្នុងករណីដែលសេចក្ដីសម្រេចរបស់តុលាការឱ្យផ្ដាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន ដោយអនុលោមតាមមាត្រា១១៥១(ការផ្ដាច់មត៌កពីសន្តតិជន) និងមាត្រា១១៥២(ការផ្ដាច់មត៌កពីសន្តតិជនដោយមតកសាសន៍) នៃក្រមរដ្ឋប្បវេណី ឬសេចក្ដីសម្រេចរបស់តុលាការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិជនដោយអនុលោមតាមមាត្រា១១៥៤(ការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិជន) នៃក្រមរដ្ឋប្បវេណី បានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់នៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំនោះ ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសេចក្ដីសម្រេចរបស់តុលាការនោះនិងសេចក្ដីបញ្ជាក់អំពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ក្នុងករណីដែលសេចក្ដីសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត ដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។

៣- ក្នុងករណីដែលសេចក្ដីសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ បានចូលជាស្ថាពរនៅសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៤- ក្នុងករណីដែលមានការរាយការណ៍ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានដែលមានសមត្ថកិច្ចត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីកំណើតរស់របស់មរតកជន។

## ជំពូកទី១០
## ការកែបញ្ជីអត្រានុកូលដ្ឋាន

### មាត្រា៨៥.- បុគ្គលដែលអាចស្នើសុំកែតម្រូវ

បុគ្គលដែលអាចស្នើសុំធ្វើការកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន រួមមាន៖

ក- សាមីខ្លួននៃបញ្ជីអត្រានុកូលដ្ឋាន។

ខ- ឪពុក ម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងករណីសុំកែតម្រូវបញ្ជីកំណើតរស់របស់អនីតិជន។

គ- ញាតិលោហិតផ្ទាល់និងសហព័ទ្ធនៃមរណជន ក្នុងករណីសុំកែតម្រូវបញ្ជីមរណភាព។

ឃ- បុគ្គលទាំងឡាយណាដែលមានផលប្រយោជន៍ស្របច្បាប់ក្នុងការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា៨៦.- ការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន

១- ក្នុងករណីដែលការចុះបញ្ជីអត្រានុកូលដ្ឋានមានកំហុស ហើយកំហុសនោះគឺជាកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច មន្ត្រីអត្រានុកូលដ្ឋានអាចកែតម្រូវកំហុសបច្ចេកទេសនោះតាមពាក្យសុំឬដោយឆន្ទានុសិទ្ធិ។

២- កំហុសបច្ចេកទេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះសំដៅដល់ទិន្នន័យដែលបានសរសេរខុសព័ត៌មានដោយមន្ត្រីអត្រានុកូលដ្ឋាន ដូចខាងក្រោម៖

ក- ការសរសេរខុសឆ្គងអក្ខរាវិរុទ្ធលើនាមត្រកូលនិង/ឬនាមខ្លួនជាអក្សរខ្មែរនិងអក្សរឡាតាំងរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ មានន័យថាសូរសំឡេងដូចគ្នា ប៉ុន្តែការសរសេរខុសគ្នា។

ខ- ការសរសេរខុសភេទពីឯកសារភ្ជាប់នៅពេលចុះបញ្ជី។

គ- ការសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយខុសពីឯកសារភ្ជាប់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឃ- ការសរសេរខុសថ្ងៃ ខែ ឆ្នាំកំណើតតាមសុរិយគតិ។

ង- ការសរសេរខុសថ្ងៃ ខែ ឆ្នាំកំណើតតាមចន្ទគតិ។

ច- ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាលនៃទីកន្លែងកំណើត ទីកន្លែងមរណភាព ឬទីលំនៅ។

ឆ- កំហុសបច្ចេកទេសផ្សេងទៀតដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៣- បែបបទនិងនីតិវិធីនៃការកែតម្រូវកំហុសបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៨៧.- ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ**

១- ក្រៅពីកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ដែលបានកំណត់នៅក្នុងមាត្រា៨៦(ការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន) នៃច្បាប់នេះ ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានត្រូវធ្វើឡើងតាមរយៈការដាក់ពាក្យសុំទៅតុលាការ។

២- ក្នុងករណីដែលមានពាក្យសុំដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ បទប្បញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

៣- ក្នុងករណីដែលសេចក្ដីសម្រេចកែតម្រូវរបស់តុលាការបានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវ ឬឃុំ សង្កាត់នៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំ ឬឃុំ សង្កាត់ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសេចក្ដីសម្រេចរបស់តុលាការនោះនិងសេចក្ដីបញ្ជាក់អំពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ។

៤- ក្នុងករណីដែលសេចក្ដីសម្រេចកែតម្រូវបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្តដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។

៥- ក្នុងករណីដែលសេចក្ដីសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះបានចូលជាស្ថាពរនៅសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៦- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានទទួលការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី៤និងកថាខណ្ឌទី៥ខាងលើនេះ ទោះបីជាគ្មានការរាយការណ៍ពីអ្នកដាក់ពាក្យសុំទៅតុលាការដែលបានកំណត់នៅក្នុងកថាខណ្ឌទី៣ខាងលើនេះក៏ដោយ ក៏មន្ត្រីអត្រានុកូលដ្ឋាននោះអាចកែតម្រូវបានដែរ។ ក្នុងករណីនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំទៅតុលាការនោះ។

៧- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវធ្វើការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ ហើយត្រូវចុះនិទ្ទេសក្នុងបញ្ជីអត្រានុកូលដ្ឋានដោយត្រូវរក្សាទុកទិន្នន័យដើម។

**មាត្រា៨៨._ ការប្ដូរនាមត្រកូលក្រោយអាពាហ៍ពិពាហ៍ឬក្រោយការលែងលះជាអាទិ៍**

ប្រសិនបើបុគ្គលណាស្នើសុំប្ដូរនាមត្រកូលរបស់ខ្លួនក្រោយពេលរៀបអាពាហ៍ពិពាហ៍ឬប្ដូរនាមត្រកូលត្រឡប់មកនាមត្រកូលដើមវិញក្រោយពេលលែងលះឬលុបចោលអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើការប្ដូរនាមត្រកូល ហើយត្រូវចុះនិទ្ទេសក្នុងបញ្ជីអត្រានុកូលដ្ឋាននោះដោយត្រូវរក្សាទុកទិន្នន័យដើម។

**មាត្រា៨៩._ ការប្ដូរឈ្មោះដោយតុលាការ**

១- ក្នុងករណីដែលឈ្មោះរបស់បុគ្គលណាម្នាក់ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសផ្ទាល់ខ្លួន ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អឬមានភាពចាំបាច់ពិសេសផ្សេងទៀតក្នុងការប្ដូរ បុគ្គលនោះអាចដាក់ពាក្យសុំប្ដូរឈ្មោះទៅតុលាការដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់អ្នកដាក់ពាក្យសុំបានដោយបញ្ជាក់អំពីមូលហេតុនៃការសុំប្ដូរនោះ។

២- បទប្បញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះរឿងក្ដីសុំប្ដូរឈ្មោះដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ។

៣- ក្នុងករណីដែលសេចក្ដីសម្រេចប្ដូរឈ្មោះរបស់តុលាការបានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការ ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានដែលត្រូវកែ ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសេចក្ដីសម្រេចរបស់តុលាការនោះនិងសេចក្ដីបញ្ជាក់អំពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ។

៤- ក្នុងករណីដែលសេចក្ដីសម្រេចប្ដូរឈ្មោះបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្តដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។

៥- ក្នុងករណីដែលសេចក្ដីសម្រេចកែតម្រូវបានចូលជាស្ថាពរនៅនៅសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៦- មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើការកែឈ្មោះក្នុងបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ ហើយត្រូវចុះនិទ្ទេសក្នុងបញ្ជីអត្រានុកូលដ្ឋានដោយត្រូវរក្សាទុកទិន្នន័យដើម។

**មាត្រា៩០._ នីតិវិធីនៃការជូនដំណឹង**

នីតិវិធីនៃការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រា៧៨ (ការចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍) កថាខណ្ឌទី២និង

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

កថាខណ្ឌទី៣នៃមាត្រា៨១(ការចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ) កថាខណ្ឌទី២និង កថាខណ្ឌទី៣នៃមាត្រា៨៤(ការចុះបញ្ជីផ្តាច់មត៌ក) កថាខណ្ឌទី៤និងកថាខណ្ឌទី៥នៃមាត្រា៨៧ (ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ) កថាខណ្ឌទី៤និងកថាខណ្ឌទី៥ នៃមាត្រា៨៩(ការប្តូរឈ្មោះដោយតុលាការ) នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួង មហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ផ្នែកទី១១

## ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន ការថែទាំ ការរក្សាទុក ការបញ្ជូនបញ្ជី ព័ត៌មាន និងរបាយការណ៍ស្តីពីការងារអត្រានុកូលដ្ឋាន

### មាត្រា៩១.- ការធ្វើបច្ចុប្បន្នភាពបញ្ជីអត្រានុកូលដ្ឋាន

១- ក្នុងករណីដែលមានការចុះបញ្ជីអត្រានុកូលដ្ឋានណាមួយ ដោយផ្អែកលើបញ្ញត្តិចាប់ពី ផ្នែកទី៣(អំពីមន្ត្រីអត្រានុកូលដ្ឋាន) ដល់ផ្នែកទី១០(ការកែបញ្ជីអត្រានុកូលដ្ឋាន) មន្ត្រីអត្រានុកូលដ្ឋាន ដែលមានសមត្ថកិច្ចត្រូវធ្វើបច្ចុប្បន្នភាពនៅក្នុងបញ្ជីផ្សេងទៀតដែលពាក់ព័ន្ធទាំងអស់។

២- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវធានាថាបច្ចុប្បន្នភាពដែលបានកំណត់នៅក្នុង កថាខណ្ឌទី១ខាងលើនេះត្រូវបានធ្វើឡើងដោយពេញលេញនិងត្រឹមត្រូវ។

៣- ទម្រង់ បែបបទ និងនីតិវិធីនៃការធ្វើបច្ចុប្បន្នភាពនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ត្រូវកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា៩២.- ការថែទាំនិងការរក្សាទុកបញ្ជី

នីតិវិធីនៃការថែទាំនិងការរក្សាទុកបញ្ជីអត្រានុកូលដ្ឋាននៅថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា៩៣.- ការរៀបចំឡើងវិញបញ្ជីអត្រានុកូលដ្ឋាន

ក្នុងករណីដែលបញ្ជីអត្រានុកូលដ្ឋានបានបាត់បង់ឬត្រូវបំផ្លាញមួយភាគឬទាំងស្រុង មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចាត់វិធានការឱ្យមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចរៀបចំ បញ្ជីអត្រានុកូលដ្ឋានទាំងនោះឡើងវិញ។

### មាត្រា៩៤.- ការបញ្ជូនបញ្ជីនិងរបាយការណ៍អត្រានុកូលដ្ឋាន

១- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវបញ្ជូនបញ្ជីអត្រានុកូលដ្ឋានជូនមន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ក្រុង ស្រុក ខណ្ឌនិង/ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្តនិង/ឬមន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ជាតិ។

២- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការងារអត្រានុកូលដ្ឋាន ប្រចាំខែជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌនិង/ឬថ្នាក់រាជធានី ខេត្ត។

៣- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការងារ អត្រានុកូលដ្ឋានជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្តនិង/ឬមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ស្ដីពីការងារអត្រានុកូលដ្ឋាន ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

៥- របៀបនិងពេលវេលានៃការបញ្ជូនបញ្ជីនិងរបាយការណ៍ ដែលបានកំណត់នៅក្នុង កថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤ខាងលើនេះ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៩៥.- ការបញ្ជូនបញ្ជីនិងរបាយការណ៍អត្រានុកូលដ្ឋានរបស់ស្ថានតំណាង**

មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបញ្ជូនបញ្ជី អត្រានុកូលដ្ឋាន និងរបាយការណ៍ស្ដីពីការងារអត្រានុកូលដ្ឋានជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ទៅតាមរបៀបនិងពេលវេលា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៩៦.- ការបញ្ជូនទិន្នន័យ**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវធានាថាទិន្នន័យនានាដែលចាំបាច់ទាក់ទងនឹងព្រឹត្តិការណ៍ ជីវិត ត្រូវបញ្ជូនទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ដូចមានចែងនៅក្នុងជំពូកទី៦ (ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ។

## ផ្នែកទី១២
## អានុភាពតាមផ្លូវច្បាប់នៃបញ្ជីអត្រានុកូលដ្ឋាននិងសំបុត្រអត្រានុកូលដ្ឋាន

**មាត្រា៩៧.- អានុភាពតាមផ្លូវច្បាប់នៃបញ្ជីអត្រានុកូលដ្ឋាននិងសំបុត្រ អត្រានុកូលដ្ឋាន**

បញ្ជីអត្រានុកូលដ្ឋាននិងសំបុត្រអត្រានុកូលដ្ឋាន ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានមាន សមត្ថកិច្ច ត្រូវសន្មតថាជាភស្តុតាងត្រឹមត្រូវតាមផ្លូវច្បាប់ចំពោះ៖

ក- ការចុះបញ្ជីព្រឹត្តិការណ៍ជីវិត ដែលទាក់ទងនឹងសំបុត្រអត្រានុកូលដ្ឋាននោះ។

ខ- ព័ត៌មានដែលមាននៅក្នុងបញ្ជីអត្រាអនុកូលដ្ឋាននិងនៅក្នុងសំបុត្រ អត្រានុកូលដ្ឋាននោះ។

## ផ្នែកទី១៣
## បណ្ដឹងមិនសុខចិត្ត

**មាត្រា៩៨.- បណ្ដឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រី អត្រានុកូលដ្ឋាន**

១- បុគ្គលដែលបានស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីចុះបញ្ជីព្រឹត្តិការណ៍ជីវិត ឬកែតម្រូវ បញ្ជីអត្រានុកូលដ្ឋាន ឬសំណើផ្សេងៗទៀត ដែលត្រូវបានអនុញ្ញាតក្រោមជំពូកនេះ អាចប្ដឹងមិន សុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការ ចាត់ចែងបាន។

២- បែបបទនិងនីតិវិធីនៃការប្ដឹងមិនសុខចិត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះមិនរារាំងការប្ដឹងទៅតុលាការដោយផ្ទាល់ឡើយ។

# ជំពូកទី៣
# ស្ថិតិអត្រានុកូលដ្ឋាន

## ផ្នែកទី១
## វិធានទូទៅ

### មាត្រា៩៩ .- គោលការណ៍ជាមូលដ្ឋាន

ស្ថិតិអត្រានុកូលដ្ឋាន ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដូចខាងក្រោម៖

- ធានាដល់ការផលិតស្ថិតិអត្រានុកូលដ្ឋានប្រកបដោយគុណភាព ត្រឹមត្រូវ ពេញលេញ ទាន់ពេលវេលានិងអាចជឿជាក់បាន
- ធានាការផ្ដល់ព័ត៌មានចាំបាច់អំពីស្ថិតិប្រជាជន ដើម្បីគាំទ្រដល់ការរៀបចំការងាររដ្ឋបាល និងការរៀបចំផែនការនានា។

## ផ្នែកទី២
## ការចងក្រង ការផលិត និងការផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន

### មាត្រា១០០ .- សមត្ថកិច្ចរបស់វិទ្យាស្ថានជាតិស្ថិតិ

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានសមត្ថកិច្ចប្រមូល កែច្នៃ ចងក្រង វិភាគ និងផលិតស្ថិតិអត្រានុកូលដ្ឋានសម្រាប់ជាតិទាំងមូលនិងដោយបែងចែកទៅតាមទីតាំងភូមិសាស្ត្រនៃរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវបោះពុម្ពនិងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន។

### មាត្រា១០១ .- ប្រភពទិន្នន័យនៃស្ថិតិអត្រានុកូលដ្ឋាន

១- ប្រភពទិន្នន័យនៃស្ថិតិអត្រានុកូលដ្ឋានបានមកពីការប្រមូលនៅក្នុងដំណើរការចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ និងព្រឹត្តិការណ៍ជីវិតផ្សេងទៀត និងពីការកត់ត្រាទារកស្លាប់កើត។

២- វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ អាចប្រើប្រាស់នូវប្រភពទិន្នន័យខាងលើនេះនិងព័ត៌មានផ្សេងទៀត ដើម្បីបំពេញបន្ថែមនូវព័ត៌មានអំពីអត្រានុកូលដ្ឋាន។

### មាត្រា១០២ .- ការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាននិងទារកស្លាប់កើត

១- ក្រសួងមហាផ្ទៃត្រូវធានាបញ្ជូនព័ត៌មានចាំបាច់ពីបញ្ជីអត្រានុកូលដ្ឋានទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឱ្យបានទៀងទាត់និងទាន់ពេលវេលា។ ក្រសួងមហាផ្ទៃមិនត្រូវបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល ដូចជាឈ្មោះ ពីបញ្ជីអត្រានុកូលដ្ឋានទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ពេលវេលា បែបបទ និងព័ត៌មានដែលត្រូវបញ្ជូន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងផែនការ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ក្រសួងសុខាភិបាលត្រូវធានាបញ្ជូនព័ត៌មានអំពីទារកស្លាប់កើតទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឱ្យបានទៀងទាត់និងទាន់ពេលវេលា។ ក្រសួងសុខាភិបាលមិនត្រូវបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល ដូចជាឈ្មោះរបស់ឪពុកម្ដាយ ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ពេលវេលា បែបបទ និងព័ត៌មានដែលត្រូវបញ្ជូន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងផែនការ។

### មាត្រា១០៣ .- ការចងក្រង ផលិត បោះពុម្ព និងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន

១- វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវចងក្រង ផលិត និងបោះពុម្ពនូវស្ថិតិអត្រានុកូលដ្ឋានឱ្យបានទាន់ពេលវេលា ត្រឹមត្រូវ ពេញលេញ និងឱ្យបានទៀងទាត់ ព្រមទាំងបែងចែកនូវរបាយការណ៍ស្ថិតិអត្រានុកូលដ្ឋានភ្លាមៗបន្ទាប់ពីការផលិតស្ថិតិអត្រានុកូលដ្ឋាននេះ យ៉ាងហោចណាស់ឱ្យបានរៀងរាល់ឆ្នាំសម្រាប់ឆ្នាំប្រតិទិននីមួយៗ និងត្រូវផ្សព្វផ្សាយអំពីស្ថិតិអត្រានុកូលដ្ឋាននៅលើគេហទំព័ររបស់ខ្លួននិងតាមមធ្យោបាយសមស្របផ្សេងទៀត។

២- ក្រៅពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលមានជាធរមាន នីតិវិធីចាំបាច់នៃការចងក្រង ផលិត បោះពុម្ព និងផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## ផ្នែកទី៣
## ការកត់ត្រានិងការបញ្ជាក់ទារកស្លាប់កើត

### មាត្រា១០៤ .- ការកត់ត្រាទារកស្លាប់កើត

មូលដ្ឋានសុខាភិបាលត្រូវកត់ត្រាព័ត៌មានអំពីទារកស្លាប់កើតនីមួយៗ ដូចខាងក្រោម៖

ក- កាលបរិច្ឆេទនិងទីកន្លែងសម្រាលទារកស្លាប់កើត។

ខ- ភេទ ទម្ងន់ អាយុគភ៌និងប្រវែងខ្លួនគភ៌ ប្រសិនបើដឹង។

គ- ការបញ្ជាក់មូលហេតុនៃទារកស្លាប់កើត ប្រសិនបើអាច។

ឃ- ថ្ងៃ ខែ ឆ្នាំកំណើតនិងលំនៅឋានរបស់ម្ដាយ។

ង- ព័ត៌មានផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៤
## ការចុះបញ្ជីស្នាក់នៅ

## ផ្នែកទី១
## វិធានទូទៅ

### មាត្រា១០៥ .- គោលការណ៍ជាមូលដ្ឋាន

ការចុះបញ្ជីស្នាក់នៅ ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម៖

- ជានាការរាប់ចំនួនមនុស្សនិងធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់បុគ្គលគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការងាររដ្ឋបាលនិងការរៀបចំផែនការនានា ជានាថាបុគ្គលគ្រប់រូបមានសិទ្ធិក្នុងការចុះបញ្ជីស្នាក់នៅ
- ពង្រឹងប្រសិទ្ធភាពនៃការបង្កើតប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យទាក់ទងនឹងការស្នាក់នៅរបស់បុគ្គលគ្រប់រូបឱ្យបានត្រឹមត្រូវដែលមានលក្ខណៈឯកភាពនៅទូទាំងប្រទេស
- ជានាយកទិន្នន័យទាក់ទងនឹងការស្នាក់នៅធ្វើជាមូលដ្ឋានមួយសម្រាប់ការផ្តល់សេវាសាធារណៈ។

## ផ្នែកទី២
## សមត្ថកិច្ចនិងមន្ត្រីចុះបញ្ជីស្នាក់នៅ

### មាត្រា១០៦ .- សមត្ថកិច្ច

ការចុះបញ្ជីស្នាក់នៅនិងការគ្រប់គ្រងការស្នាក់នៅ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

### មាត្រា១០៧ .- មន្ត្រីចុះបញ្ជីស្នាក់នៅ

១- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ គឺជាមន្ត្រីចុះបញ្ជីស្នាក់នៅ។

២- ក្នុងករណីដែលនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់អវត្តមានឬទទួលមរណភាព ឬការបញ្ឈប់មុខតំណែង នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដែលទទួលសិទ្ធិជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ស្តីទី គឺជាមន្ត្រីចុះបញ្ជីស្នាក់នៅ។

៣- បញ្ញត្តិក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ មិនរារាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការចាត់តាំងមន្ត្រីចុះបញ្ជីស្នាក់នៅផ្សេងទៀត ក្នុងករណីដែលចាំបាច់។

### មាត្រា១០៨ .- ការទទួលខុសត្រូវរបស់មន្ត្រីចុះបញ្ជីស្នាក់នៅ

មន្ត្រីចុះបញ្ជីស្នាក់នៅ ទទួលខុសត្រូវ៖

ក- ពិនិត្យ កត់ត្រា និងចុះបញ្ជីស្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ- ចេញឯកសារសម្គាល់ការស្នាក់នៅ។

គ- កែតម្រូវ លុបបញ្ជីស្នាក់នៅ ធ្វើមោឃភាពនិងដកហូតឯកសារសម្គាល់ការស្នាក់នៅ។

ឃ- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធលើការគ្រប់គ្រងការស្នាក់នៅនិងការចុះបញ្ជីស្នាក់នៅ។

ង- ចុះត្រួតពិនិត្យរដ្ឋបាលជាប្រចាំដល់លំនៅឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យផ្ទៀងផ្ទាត់អំពីការប្រែប្រួលនៃសមាជិកដែលរស់នៅក្នុងលំនៅឋាននីមួយៗ សំដៅធ្វើបច្ចុប្បន្នភាពបញ្ជីស្នាក់នៅនិងការចុះបញ្ជីស្នាក់នៅឱ្យបានពេញលេញ។

ច- ផ្សព្វផ្សាយនិងរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីស្នាក់នៅ។

ឆ- ផ្ដល់របាយការណ៍ពាក់ព័ន្ធការចុះបញ្ជីស្នាក់នៅនិងការគ្រប់គ្រងការស្នាក់នៅតាមឋានានុក្រមឱ្យបានទាន់ពេលវេលានិងត្រឹមត្រូវទៅតាមការកំណត់។

ជ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## ការចុះបញ្ជីស្នាក់នៅ

### មាត្រា១០៩ .- បញ្ជីស្នាក់នៅ

១- បញ្ជីស្នាក់នៅអាចមានទម្រង់ជាក្រដាសនិង/ឬទម្រង់ជាអេឡិចត្រូនិក។

២- ទម្រង់បញ្ជីស្នាក់នៅនិងព័ត៌មានដែលត្រូវប្រមូលនិងកត់ត្រាក្នុងបញ្ជីស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### មាត្រា១១០ .- ការចុះបញ្ជីស្នាក់នៅ

១- បុគ្គលគ្រប់រូបត្រូវចុះបញ្ជីស្នាក់នៅ នៅតាមលំនៅឋានដែលខ្លួនកំពុងរស់នៅបច្ចុប្បន្ន ដើម្បីទទួលបានការទទួលស្គាល់ការស្នាក់នៅក្នុងលំនៅឋាននោះ។

២- បុគ្គលគ្រប់រូបអាចចុះបញ្ជីស្នាក់នៅតែមួយកន្លែង ទោះបុគ្គលនោះមានលំនៅឋានច្រើនជាងមួយក៏ដោយ។

៣- បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅនៃលំនៅឋាននីមួយៗ មានកាតព្វកិច្ចចុះបញ្ជីស្នាក់នៅឱ្យសមាជិកគ្រប់រូបដែលរស់នៅជាប់លាប់ជាមួយខ្លួន។

### មាត្រា១១១ .- បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ

១- បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ រួមមាន៖

ក- អ្នកតំណាងនៃលំនៅឋាននីមួយៗ។

ខ- ម្ចាស់លំនៅឋាន ឬអ្នកឱ្យជួល ឬអ្នកតំណាង ក្នុងករណីលំនៅឋានជាកម្មវត្ថុនៃការជួល។

គ- ប្រធានអង្គភាព ឬអ្នកគ្រប់គ្រង ឬអ្នកតំណាង ក្នុងករណីលំនៅឋានដែលរស់នៅប្រមូលផ្ដុំ។

ឃ- អ្នកស្នាក់នៅជាក់ស្ដែង។

ង- បុគ្គលផ្សេងទៀត ឬប្រធានអង្គភាព ឬអ្នកគ្រប់គ្រងឬអ្នកតំណាងដែលអនុញ្ញាតដោយច្បាប់នេះឬច្បាប់ផ្សេងទៀត។

២- ក្រសួងមហាផ្ទៃអាចកំណត់បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅបន្ថែម ក្នុងករណីចាំបាច់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១១២ ._ ទីកន្លែងចុះបញ្ជីស្នាក់នៅ**

ទីកន្លែងចុះបញ្ជីស្នាក់នៅ រួមមាន៖

ក- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់នៃលំនៅឋានដែលសាមីខ្លួនកំពុងរស់នៅ។

ខ- កន្លែងផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

**មាត្រា១១៣ ._ ការរាយការណ៍សម្រាប់ចុះបញ្ជីស្នាក់នៅ**

១- បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ ត្រូវរាយការណ៍ជូនមន្ត្រីចុះបញ្ជីស្នាក់នៅអំពីសមាជិកដែលមកស្នាក់នៅក្នុងលំនៅឋាននិងត្រូវដាក់ពាក្យសុំចុះបញ្ជីស្នាក់នៅ។

២- បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ ត្រូវរាយការណ៍អំពីការផ្លាស់ចេញ ការផ្លាស់ចូល និងមរណភាពសមាជិកដែលរស់នៅជាប់លាប់ជាមួយខ្លួនជូនមន្ត្រីចុះបញ្ជីស្នាក់នៅនិងត្រូវដាក់ពាក្យសុំចុះបញ្ជីស្នាក់នៅ។

**មាត្រា១១៤ ._ ការចេញឯកសារសម្គាល់ការស្នាក់នៅ**

១- ក្រោយពេលចុះបញ្ជីស្នាក់នៅរួចរាល់ មន្ត្រីចុះបញ្ជីស្នាក់នៅត្រូវផ្តល់ឯកសារសម្គាល់ការស្នាក់នៅច្បាប់ដើម១(មួយ)ច្បាប់ជូនបុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ ដូចមានចែងនៅក្នុងមាត្រា១១១(បុគ្គលទទួលខុសត្រូវស្នើសុំចុះបញ្ជីស្នាក់នៅ) នៃជំពូកនេះ។

២- ប្រសិនបើមន្ត្រីចុះបញ្ជីស្នាក់នៅពិនិត្យឃើញថាបុគ្គលស្នើសុំចុះបញ្ជីស្នាក់នៅមានឯកសារភ្ជាប់មិនត្រឹមត្រូវ មន្ត្រីចុះបញ្ជីស្នាក់នៅអាចបដិសេធការស្នើសុំចុះបញ្ជីនោះនិងត្រូវផ្តល់មូលហេតុចំពោះការបដិសេធជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះអាចប្តឹងមិនសុខចិត្ត ដូចមានចែងនៅក្នុងផ្នែកទី៧(ការប្តឹងមិនសុខចិត្ត) នៃជំពូកនេះ។

**មាត្រា១១៥ ._ ការស្នើសុំលិខិតបញ្ជាក់ទីលំនៅ**

១- បុគ្គលដែលអាចស្នើសុំលិខិតបញ្ជាក់ទីលំនៅបាន រួមមាន៖

ក- សាមីខ្លួននៃលិខិតបញ្ជាក់ទីលំនៅ។

ខ- អ្នកតំណាងរបស់សាមីខ្លួននៃលិខិតបញ្ជាក់ទីលំនៅ។

គ- អ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលដូចមានចែងនៅក្នុងចំណុច ក និងខ។

ឃ- បុគ្គលផ្សេងទៀតដែលត្រូវបានចាត់ទុកថាមានផលប្រយោជន៍ស្របច្បាប់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

២- មន្ត្រីចុះបញ្ជីស្នាក់នៅអាចបដិសេធការស្នើសុំលិខិតបញ្ជាក់ទីលំនៅនិងត្រូវផ្តល់មូលហេតុចំពោះការបដិសេធនោះជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះអាចត្រូវបានប្តឹងមិនសុខចិត្តដូចមានចែងនៅក្នុងផ្នែកទី៧(ការប្តឹងមិនសុខចិត្ត) នៃជំពូកនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចឬតុលាការអាចទទួលបានលិខិតបញ្ជាក់ទីលំនៅសម្រាប់គោលបំណងផ្លូវច្បាប់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១១៦ ._ បែបបទនិងនីតិវិធីក្នុងការចុះបញ្ជីស្នាក់នៅ**

បែបបទនិងនីតិវិធីនៃការចុះបញ្ជីស្នាក់នៅនិងការចេញឯកសារសម្គាល់ការស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១១៧ ._ ទម្រង់ឯកសារសម្គាល់ការស្នាក់នៅ**

១- ឯកសារសម្គាល់ការស្នាក់នៅ ត្រូវមានលក្ខណៈសម្គាល់ធានាសុវត្ថិភាព ដើម្បីការពារការក្លែងបន្លំ។

២- ទម្រង់ឯកសារសម្គាល់ការស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៤
## ការកែតម្រូវ មោឃភាព ការលុបចោលបញ្ជីស្នាក់នៅ និងការដកហូតឯកសារសម្គាល់ការស្នាក់នៅ

**មាត្រា១១៨ ._ បុគ្គលដែលអាចស្នើសុំការកែតម្រូវ**

បុគ្គលដែលអាចស្នើសុំកែតម្រូវបញ្ជីស្នាក់នៅ រួមមាន៖

ក- សាមីខ្លួននៃបញ្ជីស្នាក់នៅ។

ខ- ឪពុកឬម្ដាយ ក្នុងករណីសាមីខ្លួននៃការស្នើសុំនៅជាអនីតិជន។

គ- អ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គល ដូចមានចែងក្នុងចំណុច ក និងខ។

ឃ- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ក្នុងការកែតម្រូវបញ្ជីស្នាក់នៅ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១១៩ ._ ការកែតម្រូវកំហុសក្នុងបញ្ជីស្នាក់នៅ**

១- មន្ត្រីចុះបញ្ជីស្នាក់នៅដែលគ្រប់គ្រងឬអាចចូលមើលបញ្ជីស្នាក់នៅបាន អាចកែតម្រូវកំហុសតាមការស្នើសុំឬដោយឆន្ទានុសិទ្ធិរបស់មន្ត្រីចុះបញ្ជីស្នាក់នៅ។ ការកែតម្រូវនេះត្រូវកត់ត្រានិងចុះនិទ្ទេសក្នុងបញ្ជីស្នាក់នៅដោយត្រូវរក្សាទុកទិន្នន័យដើម។

២- ប្រសិនបើមន្ត្រីចុះបញ្ជីស្នាក់នៅពិនិត្យឃើញថាសំណើសុំកែតម្រូវមិនត្រឹមត្រូវឬមានឯកសារភ្ជាប់មិនគ្រប់គ្រាន់ មន្ត្រីចុះបញ្ជីស្នាក់នៅអាចបដិសេធលើការស្នើសុំកែតម្រូវនោះជាលាយលក្ខណ៍អក្សរនិងត្រូវបញ្ជាក់អំពីមូលហេតុ។ ការបដិសេធនេះអាចប្ដឹងមិនសុខចិត្ត ដូចមានចែងក្នុងផ្នែកទី៧(ការប្ដឹងមិនសុខចិត្ត) នៃជំពូកនេះ។

៣- បែបបទនិងនីតិវិធីនៃការកែតម្រូវកំហុសក្នុងបញ្ជីស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១២០ ._ ការលុបបញ្ជីស្នាក់នៅ មោឃភាពឯកសារសម្គាល់ការស្នាក់នៅ និងការដកហូតឯកសារសម្គាល់ការស្នាក់នៅ**

១- បញ្ជីស្នាក់នៅត្រូវបានលុបក្នុងលក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- បើរកឃើញថាមានការចុះបញ្ជីស្នាក់នៅខុសនីតិវិធីកំណត់ដោយច្បាប់
- បើរកឃើញថាមានការចុះបញ្ជីស្នាក់នៅលើសពីមួយកន្លែង
- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីស្នាក់នៅបានផ្លាស់ប្តូរលំនៅឋានឬទទួលមរណភាព។

២- ឯកសារសម្គាល់ការស្នាក់នៅ ត្រូវបានធ្វើមោឃភាពក្នុងករណីណាមួយ ដូចខាងក្រោម៖

- ឯកសារសម្គាល់ការស្នាក់នៅដែលបានចេញខុសនីតិវិធីកំណត់ដោយច្បាប់ឬដោយបំពាន
- ឯកសារសម្គាល់ការស្នាក់នៅដែលបានចេញដោយបុគ្គលដែលគ្មាននីតិសម្បទា
- ឯកសារសម្គាល់ការស្នាក់នៅដែលបានចេញរួចហើយតែគ្មានគោលបញ្ជី
- ឯកសារសម្គាល់ការស្នាក់នៅដែលរកឃើញថាមានការកែឬកោសលុបទិន្នន័យដោយខ្លួនឯង។

៣- ឯកសារសម្គាល់ការស្នាក់នៅ ត្រូវបានដកហូតក្នុងករណីដែលលុបចោលឬធ្វើមោឃភាពដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើ។

៤- បញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ មិនរារាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការចេញប្រកាសកំណត់នូវលក្ខខណ្ឌផ្សេងទៀតឡើយ។

៥- បែបបទនិងនីតិវិធីនៃការលុបបញ្ជីស្នាក់នៅ ការធ្វើមោឃភាពឯកសារសម្គាល់ការស្នាក់នៅ និងការដកហូតឯកសារសម្គាល់ការស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការរក្សាទុក ការថែទាំបញ្ជីស្នាក់នៅ និងការបញ្ជូនព័ត៌មានបញ្ជីស្នាក់នៅ

### មាត្រា១២១ .- ការរក្សាទុក ការថែទាំបញ្ជីស្នាក់នៅ និងការបញ្ជូនព័ត៌មានបញ្ជីស្នាក់នៅ

១- ក្នុងករណីដែលការចុះបញ្ជីស្នាក់នៅមានទម្រង់ជាក្រដាស បញ្ជីស្នាក់នៅត្រូវរក្សាទុកនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬកន្លែងផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

២- ក្នុងករណីដែលការចុះបញ្ជីស្នាក់នៅមានទម្រង់ជាអេឡិចត្រូនិក បញ្ជីស្នាក់នៅត្រូវរក្សាទុកក្នុងប្រព័ន្ធចុះបញ្ជីស្នាក់នៅ ហើយត្រូវបញ្ជូនព័ត៌មាននានាដែលចាំបាច់ទាក់ទងនឹងការចុះបញ្ជីស្នាក់នៅទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

៣- ការរក្សាទុក ការថែទាំបញ្ជីស្នាក់នៅ និងការបញ្ជូនព័ត៌មានបញ្ជីស្នាក់នៅ ត្រូវធានាការសម្ងាត់នៃព័ត៌មានអត្តសញ្ញាណបុគ្គលនិងធានាសុវត្ថិភាព។

៤- បែបបទនិងនីតិវិធីនៃការរក្សាទុកនិងការថែទាំបញ្ជីស្នាក់នៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៦
## អានុភាពតាមផ្លូវច្បាប់នៃបញ្ជីស្នាក់នៅនិងឯកសារសម្គាល់ការស្នាក់នៅ

### មាត្រា១២២ ._ អានុភាពតាមផ្លូវច្បាប់នៃបញ្ជីស្នាក់នៅនិងឯកសារសម្គាល់ការស្នាក់នៅ

១- បញ្ជីនិងឯកសារសម្គាល់ការស្នាក់នៅ ត្រូវសន្មតថាត្រឹមត្រូវតាមផ្លូវច្បាប់ ចំពោះ៖

ក- ការចុះបញ្ជីស្នាក់នៅដែលទាក់ទងនឹងឯកសារសម្គាល់ការស្នាក់នៅដែលធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌនិងនីតិវិធីដែលកំណត់នៅក្នុងច្បាប់នេះ។

ខ- ព័ត៌មានដែលមាននៅក្នុងបញ្ជីស្នាក់នៅនិងនៅក្នុងឯកសារសម្គាល់ការស្នាក់នៅដែលធ្វើឡើងត្រឹមត្រូវតាមច្បាប់នេះ។

២- ការចុះបញ្ជីស្នាក់នៅពុំមែនជាលក្ខខណ្ឌដើម្បីទទួលបានដោយស្វ័យប្រវត្តនូវការផ្តល់សញ្ជាតិ ការផ្តល់កម្មសិទ្ធិលើអចលនទ្រព្យ និងសិទ្ធិស្របច្បាប់របស់ជនបរទេសក្នុងការតាំងទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ ការទទួលបានសិទ្ធិទាំងអស់នេះ ត្រូវកំណត់ដោយច្បាប់ដោយឡែក។

## ផ្នែកទី៧
## បណ្តឹងមិនសុខចិត្ត

### មាត្រា១២៣ ._ បណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការឃើតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីចុះបញ្ជីស្នាក់នៅ

១- បុគ្គលដែលបានស្នើសុំទៅមន្ត្រីចុះបញ្ជីស្នាក់នៅដើម្បីចុះបញ្ជីស្នាក់នៅ ឬកែតម្រូវបញ្ជីស្នាក់នៅ ឬសំណើផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតក្រោមជំពូកនេះ អាចប្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការឃើតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងបាន។

២- បែបបទនិងនីតិវិធីនៃការប្តឹងមិនសុខចិត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះមិនរារាំងការប្តឹងទៅតុលាការដោយផ្ទាល់ឡើយ។

## ជំពូកទី៥
## ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

## ផ្នែកទី១
## វិធានទូទៅ

### មាត្រា១២៤ ._ គោលការណ៍ជាមូលដ្ឋាន

ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម៖

- ជានាថាបុគ្គលមានសញ្ជាតិខ្មែរមានសិទ្ធិក្នុងការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ពង្រឹងប្រសិទ្ធភាពនៃការបង្កើតប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យអត្តសញ្ញាណបុគ្គលដែលមានសញ្ជាតិខ្មែរឱ្យបានត្រឹមត្រូវ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងពង្រឹងគុណភាពនៃឌីជីថល ដើម្បីជៀសវាងភាពស្ទួននៃអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ទិន្នន័យទាក់ទងនឹងការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរប្រើប្រាស់ធ្វើជាមូលដ្ឋានមួយក្នុងការផ្ទៀងផ្ទាត់និងការបញ្ជាក់ពីភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គលដែលមានសញ្ជាតិខ្មែរនៅពេលស្នើសុំឬផ្តល់សេវាសាធារណៈ
- ជានាការចូលរួមអនុវត្តសិទ្ធិនិងកាតព្វកិច្ចជាប្រជាពលរដ្ឋខ្មែរស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដើម្បីរួមចំណែកថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

## ផ្នែកទី២

## សមត្ថកិច្ចនិងមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

### មាត្រា១២៥.- សមត្ថកិច្ច

ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

### មាត្រា១២៦.- មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មាន៖

ក- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៃប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់។

ខ- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៃអធិការដ្ឋាននគរបាល ក្រុង ស្រុក ខណ្ឌ។

គ- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត។

ឃ- បញ្ញត្តិក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ខាងលើនេះ មិនរារាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការចាត់តាំងមន្ត្រីផ្សេងទៀតឱ្យទទួលការងារចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងករណីដែលចាំបាច់។

### មាត្រា១២៧.- ការទទួលខុសត្រូវរបស់មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទទួលខុសត្រូវ៖

ក- ពិនិត្យ កត់ត្រា និងចុះបញ្ជី ឬលើកចោលពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ- ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមការកំណត់របស់ក្រសួងមហាផ្ទៃ។

គ- រៀបចំបែបបទទាក់ទងទៅនឹងការកែតម្រូវមោឃភាព លុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសមត្ថកិច្ចពិនិត្យនិងសម្រេច។

ឃ- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធលើការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

ង- ផ្សព្វផ្សាយនិងរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីនិងការប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

ច- ផ្តល់របាយការណ៍ពាក់ព័ន្ធការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរតាមឋានានុក្រមឱ្យបានទាន់ពេលវេលានិងត្រឹមត្រូវទៅតាមការកំណត់។

ឆ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

### មាត្រា១២៨ .- បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានទម្រង់ជាអេឡិចត្រូនិក។

២- ទម្រង់និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១២៩ .- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាឯកសារផ្លូវការមួយសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណបុគ្គលម្នាក់ៗដែលមានសញ្ជាតិខ្មែរ ដោយមិនអនុញ្ញាតឱ្យធ្វើការផ្ទេរពីបុគ្គលមួយទៅបុគ្គលមួយទៀត ឬយកទៅបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សបានឡើយ។

២- ទម្រង់ លក្ខណៈសម្គាល់ ព័ត៌មាន ការកំណត់សុពលភាព និងការកំណត់អាយុត្រូវផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១៣០ .- ទីកន្លែងចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ទីកន្លែងចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រួមមាន៖

ក- ឃុំ សង្កាត់នៃលំនៅឋានដែលសាមីខ្លួនកំពុងរស់នៅ។

ខ- កន្លែងផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

### មាត្រា១៣១ .- ការស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងឧត្តមភាព

១- បុគ្គលដែលមានសញ្ជាតិខ្មែរ ហើយគ្រប់អាយុតាមការកំណត់ដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រា១២៩(អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) នៃច្បាប់នេះ អាចស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- បុគ្គលដែលមានសញ្ជាតិខ្មែរ អាចស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន តែមួយប៉ុណ្ណោះ។

៣- បុគ្គលដែលមានសញ្ជាតិខ្មែរ អាចស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថ្មីឡើងវិញបាន ក្នុងករណីដែលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់បុគ្គលនោះមានការខូចខាត ឬបាត់បង់ ឬអស់សុពលភាពឬកែតម្រូវទិន្នន័យ។

៤- ពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងសុំផ្តល់ទុតិយតា ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវភ្ជាប់ឯកសារចាំបាច់មួយចំនួនតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## មាត្រា១៣២.- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនសាមីខ្លួន

១- ក្រោយពេលចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររួចរាល់ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនសាមីខ្លួន។

២- ប្រសិនបើមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរពិនិត្យឃើញថាពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងឯកសារភ្ជាប់ខ្វះនូវព័ត៌មានណាមួយដូចបានកំណត់នៅក្នុងកថាខណ្ឌទី៤នៃមាត្រា១៣១(ការស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងទុតិយតា) នៃច្បាប់នេះ មន្ត្រីចុះអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវទាមទារឱ្យអ្នកស្នើសុំផ្តល់ព័ត៌មានដែលខ្វះនោះដោយកំណត់រយៈពេលសមរម្យ។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនផ្តល់ព័ត៌មានដែលខ្វះនៅក្នុងរយៈពេលសមរម្យដែលកំណត់ដោយមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទេ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអាចលើកចោលពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

៣- បែបបទនិងនីតិវិធីនៃការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងការផ្តល់ទុតិយតា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

# ផ្នែកទី៤
# ការកែតម្រូវ មោឃភាព ការលុបចោលបញ្ជី និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

## មាត្រា១៣៣.- ការកែតម្រូវទិន្នន័យបុគ្គលក្នុងបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- សាមីខ្លួនអាចស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណក្នុងបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់ខ្លួនបាន ក្នុងករណីដែលបញ្ជីអត្រានុកូលដ្ឋានត្រូវបានកែតម្រូវដោយអនុលោមទៅតាមបញ្ញត្តិនៃផ្នែកទី១០(ការកែបញ្ជីអត្រានុកូលដ្ឋាន) នៃជំពូកទី២(ការចុះបញ្ជីអត្រានុកូលដ្ឋាន) ឬករណីដែលបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានការកត់ត្រាខុសពីបញ្ជីអត្រានុកូលដ្ឋាន។

២- ជនណាដែលទទួលបានសញ្ជាតិខ្មែរ ហើយមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន អាចស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដោយផ្អែកលើព័ត៌មាននៅក្នុងព្រះរាជក្រឹត្យស្តីពីការចូលសញ្ជាតិរបស់ខ្លួន។

៣- ពាក្យសុំនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើ ត្រូវដាក់ទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៤- ព័ត៌មានចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យសុំកែតម្រូវបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងឯកសារភ្ជាប់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៥- ប្រសិនបើមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដូចមានកំណត់ក្នុងកថាខណ្ឌទី២ខាងលើនេះពិនិត្យឃើញថាពាក្យសុំកែតម្រូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរខ្វះនូវព័ត៌មានចាំបាច់មួយចំនួនដូចបានកំណត់នៅក្នុងកថាខណ្ឌទី៣ខាងលើ មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវទាមទារឱ្យអ្នកដាក់ពាក្យសុំកែតម្រូវផ្តល់ព័ត៌មានដែលខ្វះនោះដោយកំណត់រយៈពេលសមរម្យ។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនផ្តល់ព័ត៌មានដែលខ្វះនៅក្នុងរយៈពេលសមរម្យដែលកំណត់ដោយមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទេ មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសិទ្ធិគ្រប់គ្រងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអាចលើកចោលពាក្យសុំកែតម្រូវនោះ។

៦- បែបបទនិងនីតិវិធីនៃការកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៣៤.- ការលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មោឃភាព និង ការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

១- បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានលុបក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

- បើរកឃើញថាមានការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរខុសនីតិវិធីកំណត់ដោយច្បាប់
- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានទទួលមរណភាព
- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានបាត់សញ្ជាតិខ្មែរ។

២- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានធ្វើមោឃភាព ក្នុងករណីណាមួយដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបានចេញខុសនីតិវិធីកំណត់ដោយច្បាប់ ឬដោយបំពាន
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបានចេញដោយបុគ្គលដែលគ្មាននីតិសម្បទា
- បើរកឃើញថាបុគ្គលណាម្នាក់បានប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលនៅមានសុពលភាពលើសពី១(មួយ)

- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានទទួលមរណភាព
- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានបាត់សញ្ជាតិខ្មែរ។

៣- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានដកហូតក្នុងករណីលុបចោលឬមោឃភាព ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើ។

៤- បញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ មិនរារាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការចេញប្រកាសកំណត់នូវលក្ខខណ្ឌផ្សេងទៀតឡើយ។

៥- បែបបទនិងនីតិវិធីនៃការលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ការធ្វើមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការបញ្ជូនទិន្នន័យនិងការថែរក្សាទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

### មាត្រា១៣៥ .- ការបញ្ជូនទិន្នន័យនិងការថែរក្សាទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- ទិន្នន័យនៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបញ្ជូនដោយស្វ័យប្រវត្តទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ដូចមានចែងក្នុងជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ។

២- ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវថែរក្សាទុកដោយសុវត្ថិភាពបំផុត ដូចដែលមានចែងក្នុងជំពូកទី៧(ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គលនិងសន្តិសុខទិន្នន័យ) នៃច្បាប់នេះ។

៣- ទិន្នន័យបុគ្គលដែលកត់ត្រានិងរក្សាទុកក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវការពារនិងគ្រប់គ្រងដោយរដ្ឋ។

## ផ្នែកទី៦
## អានុភាពតាមផ្លូវច្បាប់នៃបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

### មាត្រា១៣៦ .- អានុភាពតាមផ្លូវច្បាប់នៃបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

បញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវសន្មតថាត្រឹមត្រូវតាមផ្លូវច្បាប់ ចំពោះ៖

ក- ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌនិងនីតិវិធីដែលកំណត់នៅក្នុងច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៥- ទិន្នន័យបុគ្គលដែលមាននៅក្នុងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព័ត៌មានបុគ្គលដែលបង្ហាញនៅលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងទិន្នន័យដែលបានរក្សាទុកក្នុងបន្ទះអេឡិចត្រូនិកនៃសន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលធ្វើឡើងត្រឹមត្រូវតាមច្បាប់នេះ។

## ផ្នែកទី៧
## បណ្តឹងមិនសុខចិត្ត

### មាត្រា១៣៧.- បណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- បុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដើម្បីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬកែតម្រូវបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំណើផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតក្រោមជំពូកនេះ អាចប្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងបាន។

២- បែបបទនិងនីតិវិធីនៃការប្តឹងមិនសុខចិត្តដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនរារាំងការប្តឹងទៅតុលាការដោយផ្ទាល់ឡើយ។

# ជំពូកទី៦
# ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

## ផ្នែកទី១
## វិធានទូទៅ

### មាត្រា១៣៨.- គោលការណ៍ជាមូលដ្ឋាន

ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដូចខាងក្រោម៖

- ធានាដល់ការប្រមូលផ្តុំទិន្នន័យប្រជាជនជាឌីជីថល តាមគោលការណ៍អន្តរកម្មនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រជាជននិងការធ្វើសមាហរណកម្មយន្តការអភិបាលកិច្ច ស្ថាប័នអន្តរក្រសួង សម្រាប់ឱ្យស្ថាប័នផ្សេងៗ និងសម្រាប់ឱ្យប្រព័ន្ធស្ថាប័ននោះប្រើប្រាស់ជាប្រភពទិន្នន័យប្រជាជនចម្បងនិងតែមួយគត់ដែលជាទីទុកចិត្ត
- ធានាដល់គុណភាពនិងគោលការណ៍ឯកត្តកម្មព័ត៌មានអត្តសញ្ញាណបុគ្គលនិងធានាឱ្យស្ថាប័នឬបុគ្គលតាមការអនុញ្ញាតដោយច្បាប់មានលទ្ធភាពក្នុងការស្វែងរកទិន្នន័យត្រឹមត្រូវនិងពិតប្រាកដអំពីបុគ្គល
- ធានាឱ្យបុគ្គលដែលមានសញ្ជាតិខ្មែរនិងបុគ្គលទាំងឡាយណាដែលកើតនិង/ឬស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលតែមួយគត់និងជាអចិន្ត្រៃយ៍។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

### មាត្រា១៣៩ .- ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

១- ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ជាប្រព័ន្ធស្នូលទិន្នន័យអត្តសញ្ញាណបុគ្គល។

២- ការបង្កើតនិងការអភិវឌ្ឍប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ដោយប្រើបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីភ្ជាប់និងធ្វើអន្តរកម្មជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅប្រព័ន្ធគ្រប់គ្រងទិន្នន័យ សញ្ជាតិ និងប្រព័ន្ធផ្សេងទៀត។

៣- ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

### មាត្រា១៤០ .- មុខងាររបស់ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

១- ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន មានមុខងារដូចខាងក្រោម៖

ក- បញ្ចូននិងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នូវទិន្នន័យអត្តសញ្ញាណបុគ្គលនៅក្នុងបញ្ជីប្រជាជន។

ខ- បង្កើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដោយស្វ័យប្រវត្ត។

គ- ធ្វើអន្តរកម្មរវាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ និងប្រព័ន្ធផ្សេងទៀត ដើម្បីកត់ត្រា រក្សាទុក ធ្វើបច្ចុប្បន្នភាពទិន្នន័យនិងផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល។

ឃ- បែងចែកទិន្នន័យអត្តសញ្ញាណបុគ្គលចេញពីបញ្ជីប្រជាជន។

២- ក្នុងករណីដែលចាំបាច់និងដើម្បីធានាដល់ការគ្រប់គ្រងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនឱ្យមានប្រសិទ្ធភាពខ្ពស់ អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនមានសិទ្ធិបន្ថែមមុខងាររបស់ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនបាន។

## ផ្នែកទី៣
## លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

### មាត្រា១៤១ .- ការបង្កើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវបង្កើតដោយប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនតាមរយៈការជ្រើសរើសដោយចៃដន្យនិងស្វ័យប្រវត្តសម្រាប់ផ្តល់ជូនបុគ្គលគ្រប់រូបដែលមានសញ្ជាតិខ្មែរនិងបុគ្គលទាំងឡាយណាដែលកើតនិង/ឬស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ទម្រង់និងលំដាប់លេខរៀងលម្អិតនៃលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

## មាត្រា១៤២.- ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវបានផ្តល់ជូនបុគ្គលម្នាក់ៗជាអចិន្ត្រៃយ៍ សម្រាប់ប្រើប្រាស់រហូតដល់បុគ្គលនោះទទួលមរណភាព។

២- បុគ្គលគ្រប់រូបដែលបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលបានកើតនៅក្រៅប្រទេស នៅក្រោយកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ នឹងត្រូវបានផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលតាមរយៈការស្នើសុំចុះបញ្ជីកំណើតរស់។ សម្រាប់ប្រជាពលរដ្ឋខ្មែរដែលកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនឹងត្រូវផ្តល់ជូនតាមរយៈការស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ សម្រាប់ជនអន្តោប្រវេសន៍ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬចូលសញ្ជាតិជាប្រជាពលរដ្ឋខ្មែរ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនឹងផ្តល់ជូនតាមរយៈការចុះបញ្ជីអន្តោប្រវេសន៍ឬការចុះបញ្ជីសញ្ជាតិ។

៣- នីតិវិធីនៃការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលទៅឱ្យបុគ្គលនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

## មាត្រា១៤៣.- ការបិទការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- ការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលត្រូវបានបិទ ក្នុងករណីដូចខាងក្រោម៖

ក- នៅពេលដែលម្ចាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលបានទទួលមរណភាព។

ខ- នៅពេលដែលរកឃើញថាមានការក្លែងបន្លំក្នុងការចុះបញ្ជីសញ្ជាតិ ការចុះបញ្ជីអត្រានុកូលដ្ឋានឬការចុះបញ្ជីអន្តោប្រវេសន៍។

គ- នៅពេលដែលលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលត្រូវបានផ្អាក ដោយអនុលោមតាមកថាខណ្ឌទី១នៃមាត្រា១៤៤(ការផ្អាកការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល) នៃច្បាប់នេះ ហើយលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនេះមិនបានបើកឡើងវិញ ដោយអនុលោមតាមមាត្រា១៤៥(ការបើកលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលឱ្យដំណើរការឡើងវិញ) នៃច្បាប់នេះ នៅក្នុងរយៈពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា១៤៤(ការផ្អាកការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល) នៃច្បាប់នេះ។

២- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដែលត្រូវបានបិទ មិនអាចប្រើប្រាស់ម្តងទៀតចំពោះបុគ្គលផ្សេងទៀតបានឡើយ។

## មាត្រា១៤៤.- ការផ្អាកការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- ការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវបានផ្អាក ក្នុងករណីដូចខាងក្រោម៖

ក- នៅពេលដែលបុគ្គលជាជនបរទេសបាត់បង់សិទ្ធិស្នាក់នៅឬសិទ្ធិចេញចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- នៅពេលដែលបុគ្គលទាំងឡាយណាបានលះបង់សញ្ជាតិខ្មែរនិងលែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដែលត្រូវបានផ្អាក ត្រូវរក្សាទុកក្នុងរយៈពេលដែលបានកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤៥.- ការបើកលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលឱ្យដំណើរការឡើងវិញ**

លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដែលត្រូវបានបិទឬផ្អាកការប្រើប្រាស់ ត្រូវបានបើកឱ្យដំណើរការឡើងវិញ ក្នុងករណីដែលមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនយល់ឃើញថាមូលហេតុណាមួយនៃការបិទឬការផ្អាកដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា១៤៣(ការបិទការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល) ឬកថាខណ្ឌទី១នៃមាត្រា១៤៤(ការផ្អាកការប្រើប្រាស់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល) នៃច្បាប់នេះ មិនបានកើតឡើង។

**មាត្រា១៤៦.- បែបបទនិងនីតិវិធីនៃការបិទ ការផ្អាកនិងការបើកការប្រើប្រាស់ឡើងវិញ**

បែបបទនិងនីតិវិធីនៃការបិទ ការផ្អាក និងការបើកការប្រើប្រាស់ឡើងវិញនូវលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី៤
## បញ្ជីប្រជាជន

**មាត្រា១៤៧.- បញ្ជីប្រជាជននៃប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន**

បញ្ជីប្រជាជន គឺជាប្រភពចម្បងនិងតែមួយគត់នៃទិន្នន័យប្រជាជន ដែលបានកំណត់នៅក្នុងមាត្រា១៤៨(ទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជីប្រជាជន) នៃច្បាប់នេះ។

**មាត្រា១៤៨.- ទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជីប្រជាជន**

ទិន្នន័យអត្តសញ្ញាណបុគ្គល នៅក្នុងបញ្ជីប្រជាជន រួមមាន៖

ក- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល។

ខ- ព័ត៌មានជីវប្រវត្តិ៖

- ឈ្មោះ
- ភេទ
- ថ្ងៃ ខែ ឆ្នាំកំណើត
- ទីកន្លែងកំណើត
- ឈ្មោះនិងលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់ម្តាយ
- ឈ្មោះនិងលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់ឪពុក
- សញ្ជាតិ
- ជនជាតិ ក្នុងករណីដែលមានព័ត៌មានច្បាស់លាស់
- អាសយដ្ឋានបច្ចុប្បន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- ស្ថានភាពគ្រួសារ
- លេខទូរសព្ទដៃនិង/ឬអ៊ីមែល ប្រសិនបើមាន
- ព័ត៌មានជីវប្រវត្តិចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

គ- ព័ត៌មានជីវមាត្រ៖
- រូបថតឌីជីថល
- ស្នាមខ្ចៅដៃ
- ស្នាមស្តែនប្រស្រីភ្នែក
- ក្រៅពីរូបថតឌីជីថល ស្នាមខ្ចៅដៃនិងស្នាមស្តែនប្រស្រីភ្នែកខាងលើ អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន អាចកំណត់យកព័ត៌មានជីវមាត្រផ្សេងៗទៀតតាមការចាំបាច់និងស្របតាមស្ថានភាពជាក់ស្តែង។ ក្នុងករណីដែលព័ត៌មានជីវមាត្ររបស់បុគ្គលណាម្នាក់មិនអាចធ្វើការចាប់យកបានដោយមូលហេតុពិការភាពឬមិនគ្រប់គ្រាន់តាមតម្រូវការនៃស្តង់ដាបច្ចេកទេស អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនត្រូវធ្វើសេចក្តីណែនាំដើម្បីកំណត់អំពីព័ត៌មានជំនួសព័ត៌មានជីវមាត្រដែលមិនអាចចាប់យកបាននោះ។

ឃ- ព័ត៌មានអំពីឯកសារសម្គាល់អត្តសញ្ញាណបុគ្គលដែលបានចុះបញ្ជីរួច។

**មាត្រា១៤៩ ._ ការផ្លាស់ប្តូរ ការកែតម្រូវ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យ**

ការផ្លាស់ប្តូរ ការកែតម្រូវ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យដែលបានចុះបញ្ជីក្នុងបញ្ជីប្រជាជន ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

**មាត្រា១៥០ ._ ការគ្រប់គ្រង ការរក្សាទុក និងការបែងចែកទិន្នន័យអត្តសញ្ញាណបុគ្គល**

១- មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនទទួលខុសត្រូវក្នុងការគ្រប់គ្រង រក្សាទុក និងបែងចែកទិន្នន័យអត្តសញ្ញាណបុគ្គលនៅក្នុងបញ្ជីប្រជាជនប្រកបដោយសុវត្ថិភាពបំផុត ដូចមានចែងនៅក្នុងជំពូកទី៧(ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គលនិងសន្តិសុខទិន្នន័យ) នៃច្បាប់នេះ។

២- ទិន្នន័យអត្តសញ្ញាណបុគ្គលដែលកត់ត្រានិងរក្សាទុកក្នុងបញ្ជីប្រជាជន ត្រូវការពារនិងគ្រប់គ្រងដោយរដ្ឋ។

## ផ្នែកទី៥

## អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន

**មាត្រា១៥១ ._ ការបង្កើតអាជ្ញាធរជាតិ**

១- ត្រូវបានបង្កើតអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនសម្រាប់ដឹកនាំ គ្រប់គ្រង និង

ធានាដល់ការរៀបចំនិងការធ្វើបច្ចុប្បន្នភាពនូវកំណត់ត្រាអត្តសញ្ញាណបុគ្គលនិងការប្រើប្រាស់ទិន្នន័យ។ អាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ជាសេនាធិការ។

២- ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

# ជំពូកទី៧
# ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គល និងសន្តិសុខទិន្នន័យ

## ផ្នែកទី១
## ការប្រើប្រាស់ទិន្នន័យ

### មាត្រា១៥២.- សិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល

១- បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គលរបស់ខ្លួន ដែលបានកត់ត្រានិងរក្សាទុកក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បញ្ជីស្នាក់នៅ បញ្ជីសញ្ជាតិនិងបញ្ជីលិខិតឆ្លងដែន តាមរយៈការបំពេញពាក្យស្នើសុំដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

២- ពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គលដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ អាចធ្វើឡើងដោយសាមីខ្លួន ឬបុព្វញាតិផ្ទាល់ ឬបច្ឆាញាតិផ្ទាល់ ឬសហព័ទ្ធរបស់សាមីខ្លួនឬបុគ្គលទាំងឡាយណាដែលមានផលប្រយោជន៍ស្របច្បាប់។

៣- ក្នុងករណីដែលសាមីខ្លួនជាអនីតិជនឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ ពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល អាចធ្វើឡើងដោយអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅបាន។

៤- ពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់បុគ្គល ត្រូវភ្ជាប់ជាមួយនឹងឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់អ្នកស្នើសុំនិង/ឬអ្នកតំណាងអ្នកស្នើសុំ។

៥- បែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៦- អាជ្ញាធរមានសមត្ថកិច្ចអាចបដិសេធពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់បុគ្គល ក្នុងករណីដែលពាក្យស្នើសុំនោះមិនបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។ រាល់ការបដិសេធពាក្យស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់បុគ្គល ត្រូវមានការបញ្ជាក់អំពីមូលហេតុ។

### មាត្រា១៥៣.- សម្រង់ព័ត៌មានអត្តសញ្ញាណបុគ្គល

១- សម្រង់ព័ត៌មានដែលផ្ដល់ជូនអ្នកស្នើសុំ គឺត្រូវមានព័ត៌មានដូចគ្នាទាំងស្រុងទៅនឹងព័ត៌មានដែលមានការកត់ត្រានិងរក្សាទុកក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បញ្ជីស្នាក់នៅ បញ្ជីសញ្ជាតិនិងបញ្ជីលិខិតឆ្លងដែន។

២- រាល់សម្រង់ព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់បុគ្គលដែលផ្តល់ជូនអ្នកស្នើសុំត្រូវមានការបញ្ជាក់ពីអាជ្ញាធរដែលមានសមត្ថកិច្ច។

**មាត្រា១៥៤.- ការកែតម្រូវសម្រង់ព័ត៌មាន**

១- ក្នុងករណីដែលសម្រង់ព័ត៌មានដែលផ្តល់ជូនអ្នកស្នើសុំមិនពេញលេញឬមិនត្រឹមត្រូវ អ្នកស្នើសុំអាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចឱ្យបំពេញបន្ថែមឬកែតម្រូវព័ត៌មាននោះ ដោយភ្ជាប់ជាមួយឯកសារជាផ្លូវការឬភស្តុតាង។ ប្រសិនបើអ្នកស្នើសុំមិនមែនជាសាមីខ្លួន ហើយជនដែលជាសាមីខ្លួននោះនៅរស់ អាជ្ញាធរមានសមត្ថកិច្ចអាចបំពេញបន្ថែមឬកែតម្រូវព័ត៌មានបានលុះត្រាតែមានការជូនដំណឹងនិងមានការយល់ព្រមពីសាមីខ្លួននោះ ប្រសិនបើសាមីខ្លួនជានីតិជន។ ក្នុងករណីដែលសាមីខ្លួនជាអនីតិជនឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងនិងទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ។

២- ការស្នើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើដូចខាងក្រោម៖

ក- ក្នុងករណីដែលមានការស្នើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំដោយអនុលោមទៅតាមបញ្ញត្តិនៃមាត្រា៨៥(បុគ្គលដែលអាចស្នើសុំកែតម្រូវ) និងមាត្រា៨៧(ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ) នៃជំពូកទី២(ការចុះបញ្ជីអត្រានុកូលដ្ឋាន) នៃច្បាប់នេះ។

ខ- ក្នុងករណីដែលមានការស្នើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាននៅក្នុងបញ្ជីស្នាក់នៅអ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំដោយអនុលោមទៅតាមបញ្ញត្តិនៃមាត្រា១១៩(ការកែតម្រូវកំហុសក្នុងចុះបញ្ជីស្នាក់នៅ) នៃជំពូកទី៤(ការចុះបញ្ជីស្នាក់នៅ) នៃច្បាប់នេះ។

គ- ក្នុងករណីដែលមានការស្នើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាននៅបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំដោយអនុលោមទៅតាមបញ្ញត្តិនៃមាត្រា១៣៣(ការកែតម្រូវទិន្នន័យបុគ្គលក្នុងបញ្ជីនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) នៃជំពូកទី៥(ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) នៃច្បាប់នេះ។

ឃ- ក្នុងករណីដែលមានការស្នើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាននៅបញ្ជីផ្សេងទៀតក្រៅពីបញ្ជីដូចដែលបានកំណត់នៅក្នុងចំណុច ក ខ និងគ ខាងលើនេះ អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំទៅស្ថាប័នឬអង្គភាពដែលគ្រប់គ្រងបញ្ជីនោះ ដើម្បីធ្វើការកែតម្រូវ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ង- ក្នុងករណីដែលមានព័ត៌មានមិនពេញលេញឬមិនត្រឹមត្រូវនៅលើសម្រង់ព័ត៌មាន ដែលបានចេញឱ្យដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ហើយ អ្នកស្នើសុំពុំអាចដឹងអំពីប្រភពនៃព័ត៌មានមិនពេញលេញឬមិនត្រឹមត្រូវនោះ អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណ ប្រជាជន។ បន្ទាប់ពីមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនពិនិត្យ ឃើញថាប្រភពពីបញ្ជីដែលមានព័ត៌មានមិនពេញលេញឬមិនត្រឹមត្រូវនោះស្ថិត នៅក្នុងបញ្ជីណាមួយ មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនត្រូវ ជូនដំណឹងទៅអ្នកស្នើសុំនិងណែនាំឱ្យដាក់ពាក្យស្នើសុំបំពេញបន្ថែមឬកែតម្រូវ នោះទៅអាជ្ញាធរដែលមានសមត្ថកិច្ច ដោយអនុលោមតាមបញ្ញត្តិនៃចំណុច ក ខ គ ឬឃ ខាងលើនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការបដិសេធសំណើសុំបំពេញបន្ថែមឬកែតម្រូវព័ត៌មាន អត្តសញ្ញាណបុគ្គលដោយមានបញ្ជាក់មូលហេតុជាលាយលក្ខណ៍អក្សរ។

## មាត្រា១៥៥.- ទិន្នន័យនៃបញ្ជីប្រជាជន

ទិន្នន័យក្នុងបញ្ជីប្រជាជន គឺជាប្រភពព័ត៌មានផ្លូវការនៃទិន្នន័យបុគ្គល។

## មាត្រា១៥៦.- ការប្រើប្រាស់ទិន្នន័យក្នុងបញ្ជីប្រជាជន

១- អាជ្ញាធរមានសមត្ថកិច្ចនៃគ្រឹះស្ថានសាធារណៈអាចប្រើប្រាស់ទិន្នន័យនៅក្នុងបញ្ជីប្រជាជន បាន ដើម្បីបំពេញមុខងារសាធារណៈដែលច្បាប់បានប្រគល់ជូនគ្រឹះស្ថានទាំងនេះ រួមទាំងសម្រាប់ គោលបំណងការងាររដ្ឋបាល សេដ្ឋកិច្ច ពន្ធដារ ស្ថិតិ ការអប់រំ សុខាភិបាល សង្គមកិច្ច សន្តិសុខ យុត្តិធម៌ ការបោះឆ្នោតនិងការងារផ្សេងទៀតដែលបម្រើដល់ផលប្រយោជន៍សាធារណៈ។ ទិន្នន័យដែល ត្រូវបានចែករំលែកសម្រាប់បំពេញមុខងារសាធារណៈ ត្រូវមានកម្រិតត្រឹមវិសាលភាពដែលមានភាព ចាំបាច់និងសមាមាត្រទៅនឹងការប្រើប្រាស់ជាក់លាក់។ ទិន្នន័យត្រូវចែករំលែកក្នុងលក្ខណៈមួយដែល ធានាបាននូវការរក្សាការសម្ងាត់នៃទិន្នន័យអត្តសញ្ញាណបុគ្គល ស្របតាមមាត្រា១៥៩(ការរក្សាការ សម្ងាត់ទិន្នន័យអត្តសញ្ញាណបុគ្គល) នៃច្បាប់នេះ។

២- អ្នកផ្តល់សេវាសាធារណៈនិងឯកជន អាចប្រើប្រាស់បញ្ជីប្រជាជនឬសមាសធាតុផ្សេង ទៀតនៃប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ។ សេវាផ្ទៀងផ្ទាត់អត្តសញ្ញាណ នេះនឹងផ្តល់ការឆ្លើយតបជាមួយនឹងចម្លើយជាសារថា ត្រឹមត្រូវឬមិនត្រឹមត្រូវប៉ុណ្ណោះ និងពុំមាន ការចែករំលែកទិន្នន័យឬព័ត៌មានអត្តសញ្ញាណបុគ្គលក្នុងលក្ខណៈជាផ្នែកមួយនៃសារឆ្លើយតបទៅ នឹងសំណើផ្ទៀងផ្ទាត់អត្តសញ្ញាណឡើយ។

## មាត្រា១៥៧.- ការផលិតទិន្នន័យស្ថិតិចេញពីបញ្ជីប្រជាជន

១- ប្រធានមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន អាចសម្រេចអនុញ្ញាតឬ បដិសេធចំពោះសំណើរបស់បុគ្គល ឬគ្រឹះស្ថាន ឬអង្គភាពណាមួយ ដើម្បីផលិតទិន្នន័យស្ថិតិចេញ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ពីបញ្ជីប្រជាជន។ ក្នុងករណីដែលប្រធានមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនសម្រេចអនុញ្ញាតផលិតទិន្នន័យចេញពីបញ្ជីប្រជាជន ការប្រើប្រាស់ទិន្នន័យនោះ ត្រូវតែមានការព្រមព្រៀងរវាងមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងអ្នកស្នើសុំ និងត្រូវរក្សានូវការការពារឯកជនភាពបុគ្គល សន្តិសុខ និងការសម្ងាត់។

២- នៅពេលដែលទិន្នន័យផលិតចេញពីបញ្ជីប្រជាជនត្រូវបានប្រគល់ឱ្យអ្នកស្នើសុំទិន្នន័យទាំងនោះ មិនគួរមានព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់បុគ្គលណាមួយដែលមានហានិភ័យនាំឱ្យមានការលាតត្រដាងអំពីអត្តសញ្ញាណរបស់បុគ្គលបានឡើយ។

### មាត្រា១៥៨.- បណ្ដឹងមិនសុខចិត្តចំពោះសេចក្ដីសម្រេចឬការបដិសេធ ទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល

១- បុគ្គលគ្រប់រូបមានសិទ្ធិប្ដឹងមិនសុខចិត្តចំពោះសេចក្ដីសម្រេចឬការបដិសេធទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល ដូចបានកំណត់នៅក្នុងមាត្រា១៥២(សិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល) ឬការកែតម្រូវសម្រង់ព័ត៌មាន ដូចបានកំណត់នៅក្នុងមាត្រា១៥៤(ការកែតម្រូវសម្រង់ព័ត៌មាន) នៃច្បាប់នេះ។

២- បណ្ដឹងមិនសុខចិត្ត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើដូចខាងក្រោម៖

- ក- បណ្ដឹងមិនសុខចិត្តទាក់ទងនឹងការសម្រេចឬការបដិសេធដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវប្ដឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលសេចក្ដីសម្រេចឬការបដិសេធនោះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្រេចលើបណ្ដឹងមិនសុខចិត្តនេះ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលបណ្ដឹងមិនសុខចិត្តនោះ។ នីតិវិធីនៃការប្ដឹងមិនសុខចិត្តទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ខ- ក្នុងករណីបុគ្គលណាម្នាក់មិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បុគ្គលនោះអាចដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេច ឬការបដិសេធនោះ។

៣- បណ្ដឹងចំពោះសេចក្ដីសម្រេចឬការបដិសេធដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ដូចបានបញ្ញត្តនៅក្នុងចំណុច ង នៃកថាខណ្ឌទី២ នៃមាត្រា១៥៤(ការកែតម្រូវសម្រង់ព័ត៌មាន) នៃច្បាប់នេះ ត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ចដោយផ្ទាល់ នៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីទទួលបានសេចក្ដីសម្រេចឬការបដិសេធនោះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## ការការពារឯកជនភាពបុគ្គល

### មាត្រា១៥៩ .- ការរក្សាការសម្ងាត់ទិន្នន័យអត្តសញ្ញាណបុគ្គល

១- ព័ត៌មានដែលមាននៅក្នុងបញ្ជីត្រូវបានការពារ។ ការរក្សាការសម្ងាត់នៃព័ត៌មានឯកជននៃបុគ្គលដែលបានកត់ត្រានិងរក្សាទុកនៅក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបញ្ជីអត្តសញ្ញាណបុគ្គលផ្សេងទៀត ដែលស្ថិតនៅក្រោមច្បាប់នេះ ត្រូវបានការពារ។

២- បញ្ជីឈ្មោះបុគ្គលដែលមាននៅក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបញ្ជីអត្តសញ្ញាណបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោមច្បាប់នេះ មិនត្រូវផ្សព្វផ្សាយឬបង្ហាញដោយបុគ្គលឬគ្រឹះស្ថានឬអង្គភាពណាមួយដែលមិនទទួលបានការអនុញ្ញាតពីច្បាប់ ឬពីលិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## សន្តិសុខទិន្នន័យ

### មាត្រា១៦០ .- សុវត្ថិភាពទិន្នន័យក្នុងពេលប្រមូល បញ្ជូន ប្រើប្រាស់និងផ្ទុកទិន្នន័យ

១- ការប្រមូល ការបញ្ជូន ការប្រើប្រាស់និងការផ្ទុកទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលធានាបាននូវសន្តិសុខ សុក្រឹតភាព សុចរិតភាពទិន្នន័យ ការពារទិន្នន័យមិនឱ្យមានការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនិងធានាមិនឱ្យមានការបាត់បង់។

២- នីតិវិធីនៃការប្រមូល ការបញ្ជូន ការប្រើប្រាស់និងការផ្ទុកទិន្នន័យ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃឬក្រសួងឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

### មាត្រា១៦១ .- សិទ្ធិរបស់មន្ត្រីសាធារណៈក្នុងការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល

១- សិទ្ធិរបស់មន្ត្រីសាធារណៈក្នុងការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលត្រូវបានកម្រិតឱ្យប្រើប្រាស់បានតែចំពោះទិន្នន័យអត្តសញ្ញាណបុគ្គល ដែលចាំបាច់សម្រាប់បំពេញមុខងារសាធារណៈរបស់មន្ត្រីសាធារណៈនោះប៉ុណ្ណោះ។

២- បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលដោយមន្ត្រីសាធារណៈ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១៦២ .- ការរក្សាទុកជាឯកសារបណ្ណសារអចិន្ត្រៃយ៍

១- ទោះបីជាមានបញ្ញត្តនៅក្នុងច្បាប់ស្តីពីបណ្ណសារក៏ដោយ ចំពោះ៖

ក- បញ្ជីអត្រានុកូលដ្ឋាននិងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ខ- បញ្ជីប្រជាជនត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

គ- បញ្ជីស្នាក់នៅ បញ្ជីសញ្ជាតិ បញ្ជីលិខិតឆ្លងដែន និងបញ្ជីអន្តោប្រវេសន៍ ត្រូវរក្សាទុកនៅក្រសួងមហាផ្ទៃ។

២- រយៈពេលនៃការរក្សាទុកបញ្ជីដូចបានបញ្ញត្តនៅក្នុងចំណុច គ នៃកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៨
## កម្រៃសេវា

### មាត្រា១៦៣ .- វិសាលភាពនៃសេវា

សេវានៃជំពូកនេះ សំដៅដល់សេវាដែលបានកំណត់នៅក្នុងជំពូកទី២(ការចុះបញ្ជីអត្រានុកូលដ្ឋាន) ជំពូកទី៣(ស្ថិតិអត្រានុកូលដ្ឋាន) ជំពូកទី៤(ការចុះបញ្ជីស្នាក់នៅ) ជំពូកទី៥(ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) និងជំពូកទី៧(ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គលនិងសន្តិសុខទិន្នន័យ) នៃច្បាប់នេះ។

### មាត្រា១៦៤ .- សេវាដែលមិនតម្រូវឱ្យបង់កម្រៃ

សេវាដែលមិនតម្រូវឱ្យបង់កម្រៃ រួមមាន៖

ក- សេវាចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ និងការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន។

ខ- សេវាចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ។

គ- សេវាចុះបញ្ជីស្នាក់នៅ។

ឃ- សេវាផ្សេងទៀតដែលមិនតម្រូវឱ្យបង់កម្រៃសេវា ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១៦៥ .- ការកំណត់កម្រៃសេវាដែលត្រូវបង់

១- ក្រៅពីសេវាដែលមិនតម្រូវឱ្យបង់កម្រៃ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៤(សេវាដែលមិនតម្រូវឱ្យបង់កម្រៃ) នៃច្បាប់នេះ ស្ថាប័នដែលមានសមត្ថកិច្ចអាចយកកម្រៃសេវាបាន។

២- កម្រៃសេវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៩
## ការត្រួតពិនិត្យនិងអធិការកិច្ច

### មាត្រា១៦៦ .- ការត្រួតពិនិត្យនិងអធិការកិច្ច

១- ការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ អត្តសញ្ញាណកម្ម និងការងារផ្សេងទៀតដែលបានកំណត់នៅក្នុងច្បាប់នេះ ត្រូវទទួលការត្រួតពិនិត្យនិងការធ្វើសវនកម្ម និងអធិការកិច្ច ដោយមានលក្ខណៈជាប្រព័ន្ធ។

២- របៀបបទ លក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យនិងការធ្វើសវនកម្មផ្ទៃក្នុងឬអធិការកិច្ច ត្រូវកំណត់ដោយក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

### មាត្រា១៦៧.- អំពើមិនចុះបញ្ជីអត្រានុកូលដ្ឋាននិងបញ្ជីផ្សេងៗ

អំពើរបស់មន្ត្រីចុះបញ្ជីដែលបដិសេធដោយចេតនាដោយគ្មានមូលហេតុចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន ឬការចុះបញ្ជីស្នាក់នៅ ឬការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលច្បាប់នេះតម្រូវឱ្យចុះបញ្ជីឬបដិសេធកត់ត្រាព័ត៌មានទាក់ទងនឹងអត្រានុកូលដ្ឋាន ឬការស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលច្បាប់នេះតម្រូវឱ្យកត់ត្រា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល។

### មាត្រា១៦៨.- អំពើធ្វើឱ្យខូចខាតឬបំផ្លាញឬធ្វើឱ្យបាត់បង់បញ្ជីដោយចេតនា

មន្ត្រីដែលមានសមត្ថកិច្ចរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ដែលច្បាប់នេះតម្រូវឱ្យរក្សាទុក ហើយបានធ្វើឱ្យខូចខាត ឬបំផ្លាញ ឬធ្វើឱ្យបាត់បង់បញ្ជីនោះដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ។

### មាត្រា១៦៩.- អំពើលុបឬកែប្រែព័ត៌មាននៅក្នុងបញ្ជីឬបញ្ចូលទិន្នន័យមិនពិតនៅក្នុងបញ្ជី

មន្ត្រីដែលមានសមត្ថកិច្ចគ្រប់គ្រងបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬបញ្ជីប្រជាជនដែលបានលុប ឬកែប្រែព័ត៌មាននៅក្នុងបញ្ជី ឬបញ្ចូលទិន្នន័យមិនពិតទៅក្នុងបញ្ជីនោះដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ ១០(ដប់)ឆ្នាំ។

### មាត្រា១៧០.- អំពើចូលដល់បញ្ជីដោយចេតនា

១- មន្ត្រីដែលគ្មានសមត្ថកិច្ចចូលដល់បញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ហើយបានចូលដល់បញ្ជីនោះដោយចេតនា ឬមន្ត្រីដែលមានសមត្ថកិច្ចចូលដល់បញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ហើយបានចូលដល់បញ្ជីនោះដោយចេតនាហួសពីសមត្ថកិច្ចរបស់ខ្លួន ឬមន្ត្រីដែលមានសមត្ថកិច្ចហើយបានអនុញ្ញាតឱ្យអ្នកផ្សេងទៀតចូលដល់ឬចែករំលែកព័ត៌មានពីបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

២- ក្នុងករណីដែលអំពើដែលបានប្រព្រឹត្តដូចបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ បណ្តាលឱ្យមានការខូចខាតដល់បញ្ជីឬប្រព័ន្ធប្រព្រឹត្តកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១៧១ ._ អំពើផ្តល់ព័ត៌មានឬឯកសារក្លែងក្លាយដោយចេតនា សម្រាប់ការចុះបញ្ជី ការកត់ត្រា ឬការជូនដំណឹង**

បុគ្គលដែលផ្តល់ព័ត៌មានឬឯកសារក្លែងក្លាយដោយចេតនាសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ឬការចុះបញ្ជីស្នាក់នៅ ឬការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសម្រាប់កត់ត្រា ឬជូនដំណឹងទាក់ទងនឹងអត្រានុកូលដ្ឋាន ឬការស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ ៣ ០០០ ០០០(បីលាន)រៀល។

**មាត្រា១៧២ ._ អំពើក្លែងបន្លំ ឬកែប្រែសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លង ឬសម្រង់នៃបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ដោយចេតនា**

បុគ្គលដែលក្លែងបន្លំឬកែប្រែដោយចេតនានូវសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លង ឬសម្រង់នៃបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ ១០(ដប់)ឆ្នាំ។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ
### ផ្នែកទី១
### លិខិតបទដ្ឋានគតិយុត្តនិងនីតិវិធី ដែលមានមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

**មាត្រា១៧៣ ._ អន្តរកាលនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលមានកន្លងមក**

នៅពេលដែលច្បាប់នេះមានអានុភាពអនុវត្ត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងស្ថិតិអត្រានុកូលដ្ឋានដែលកំពុងអនុវត្តនៅតែមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងច្បាប់នេះ។

**មាត្រា១៧៤ ._ នីតិវិធីដែលបានចាប់ផ្តើមមុនពេលច្បាប់នេះត្រូវបានអនុវត្ត**

ក្រោយពេលច្បាប់នេះត្រូវបានអនុវត្ត នីតិវិធីណាដែលបានចាប់ផ្តើមហើយដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តចាស់តែមិនទាន់ចប់ ត្រូវបន្តនីតិវិធីដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត

## ផ្នែកទី២
## ព្រឹត្តិការណ៍ជីវិតនិងសេចក្ដីសម្រេចរបស់តុលាការ ដែលកើតមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

### មាត្រា១៧៥ .- ព្រឹត្តិការណ៍កំណើតរស់ឬមរណភាពដែលកើតឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

១- ព្រឹត្តិការណ៍កំណើតរស់ឬមរណភាព ដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ តែមិនទាន់បានដាក់ពាក្យសុំចុះបញ្ជីត្រឹមកាលបរិច្ឆេទនៃការអនុវត្ត ត្រូវធ្វើការចុះបញ្ជីតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណ ដូចបានបញ្ញត្តនៅក្នុងមាត្រា៦០(ការចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណ) នៃច្បាប់នេះ។

### មាត្រា១៧៦ .- សេចក្ដីសម្រេចរបស់តុលាការដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋានមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

១- សេចក្ដីសម្រេចរបស់តុលាការទាំងឡាយណាដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ដូចជាការលែងលះ បិតុភាព មាតុភាព សុំកូន ការផ្ដាច់មត៌កនិងការកែតម្រូវកំហុសនានាដែលបានចូលជាស្ថាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អ្នកដាក់ពាក្យសុំទៅតុលាការឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចរបស់តុលាការ អាចរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចបាន។

២- សេចក្ដីសម្រេចរបស់តុលាការដែលទាក់ទងនឹងការប្ដូរឈ្មោះដែលបានចូលជាស្ថាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អ្នកដាក់ពាក្យសុំទៅតុលាការ ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ស្របតាមបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៨៩(ការប្ដូរឈ្មោះដោយតុលាការ) នៃច្បាប់នេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

## ផ្នែកទី១
## សុពលភាពនៃកំណត់ត្រាដែលមានកន្លងមក នីតិវិធីកន្លងមក និងបទប្បញ្ញត្តិច្បាប់ផ្សេងទៀត

### មាត្រា១៧៧ .- សុពលភាពនៃកំណត់ត្រាដែលមានមុនកាលបរិច្ឆេទនៃការអនុវត្តជាទូទៅនៃច្បាប់នេះ

១- រាល់កំណត់ត្រានៅក្នុងបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ត្រូវបន្តមានសុពលភាពដូចគ្នាទៅនឹងកំណត់ត្រាអត្រានុកូលដ្ឋាន កំណត់ត្រាបញ្ជីស្នាក់នៅឬកំណត់ត្រាបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលធ្វើឡើងក្រោមច្បាប់នេះ។

២- រាល់សំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលនៅមានសុពលភាព ដែលបានចេញមុនកាលបរិច្ឆេទអនុវត្តជាទូទៅនិងរាល់សេចក្ដីចម្លងឬសម្រង់ដែលមានការបញ្ជាក់ដែលចេញពីកំណត់ត្រាអត្រានុកូលដ្ឋាននិងកំណត់ត្រាស្នាក់នៅដែលធ្វើឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ត្រូវបន្តមានសុពលភាពដូចនឹងសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងសេចក្ដីចម្លងឬសម្រង់ដែលចេញក្រោមច្បាប់នេះ។

## ផ្នែកទី២
## កាលបរិច្ឆេទនៃការអនុវត្តច្បាប់

### មាត្រា១៧៨ .- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ

១- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ រួមមានកាលបរិច្ឆេទនៃការអនុវត្តជាទូទៅនិងកាលបរិច្ឆេទនៃការអនុវត្តដូចមានបញ្ញត្តនៅក្នុងមាត្រា១៧៩(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) មាត្រា១៨០(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព) និងមាត្រា១៨១(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ) នៃច្បាប់នេះ។

២- បទប្បញ្ញត្តិនៃច្បាប់នេះលើកលែងតែបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា១៧៩(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) មាត្រា១៨០(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព) និងមាត្រា១៨១(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ) នៃច្បាប់នេះ ត្រូវអនុវត្តភ្លាមនៅកាលបរិច្ឆេទដែលរយៈពេល១២(ដប់ពីរ)ខែ បានកន្លងផុតក្រោយពេលច្បាប់នេះចូលជាធរមាន។ កាលបរិច្ឆេទនេះហៅថា កាលបរិច្ឆេទអនុវត្តជាទូទៅ។

### មាត្រា១៧៩ .- កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិខាងក្រោមត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ ក្រោយពីបានបង្កើតនិងដាក់ឱ្យដំណើរការអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន៖

ក- មាត្រា២៦(ការផ្ដល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល)។

ខ- មាត្រា៥៨(ការបិទអត្តសញ្ញាណខាងផ្លូវច្បាប់របស់មរណជន)។

គ- មាត្រា៩៦(ការបញ្ជូនទិន្នន័យ)។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឃ- កថាខណ្ឌទី២ នៃមាត្រា១២១(ការរក្សាទុក ការថែទាំបញ្ជីស្នាក់នៅ និងការបញ្ជូនព័ត៌មានបញ្ជីស្នាក់នៅ)។

ង- កថាខណ្ឌទី១ នៃមាត្រា១៣៥(ការបញ្ជូនទិន្នន័យនិងការថែរក្សាទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ)។

ច- រាល់មាត្រានៃជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) គិតចាប់ពីមាត្រា១៣៨ រហូតដល់មាត្រា១៥១។

ឆ- ចំណុច ង នៃកថាខណ្ឌទី២ មាត្រា១៥៤(ការកែតម្រូវសម្រង់ព័ត៌មាន)។

ជ- មាត្រា១៥៥(ទិន្នន័យនៃបញ្ជីប្រជាជន)។

ឈ- មាត្រា១៥៦(ការប្រើប្រាស់ទិន្នន័យក្នុងបញ្ជីប្រជាជន)។

ញ- មាត្រា១៥៧(ការផលិតទិន្នន័យស្ថិតិចេញពីបញ្ជីប្រជាជន)។

ដ- កថាខណ្ឌទី៣ នៃមាត្រា១៥៨(បណ្តឹងមិនសុខចិត្តចំពោះសេចក្តីសម្រេច ឬការបដិសេធទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល)។

**មាត្រា១៨០ ._ កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព**

១- ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលខាងក្រោម ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- កថាខណ្ឌទី៣ នៃមាត្រា២១(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល)។

ខ- កថាខណ្ឌទី១ នៃមាត្រា២២(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាល)។

គ- កថាខណ្ឌទី៣ នៃមាត្រា៤៥(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល)។

ឃ- កថាខណ្ឌទី២ នៃមាត្រា៤៦(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល)។

ង- មាត្រា៤៧(ការជូនដំណឹងអំពីមរណភាពបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ)។

២- ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិខាងក្រោមពាក់ព័ន្ធនឹងការបញ្ជាក់អំពីមូលហេតុនៃមរណភាព ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- មាត្រា៤៨(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតី)

ខ- កថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា៤៩(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពខុសប្រក្រតីឬគួរឱ្យសង្ស័យ)

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ- មាត្រា៥០ (លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ)។

## មាត្រា១៨១ .- កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ

ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការខាងក្រោមត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- កថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា៧៨ (ការចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍)។

ខ- មាត្រា៧៩ (នីតិវិធីចុះបញ្ជីអំពីការលែងលះ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍)។

គ- កថាខណ្ឌទី២ នៃមាត្រា៨១ (ការចុះបញ្ជីតាមសេចក្ដីសម្រេចរបស់តុលាការ)។

ឃ- កថាខណ្ឌទី២ នៃមាត្រា៨៤ (ការចុះបញ្ជីផ្ដាច់មត៌ក)។

ង- កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃមាត្រា៨៧ (ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ)។

ច- កថាខណ្ឌទី៤ នៃមាត្រា៨៩ (ការប្ដូរឈ្មោះដោយតុលាការ)។

## មាត្រា១៨២ .- ការធ្វើឱ្យនិរាករណ៍បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះត្រូវបានអនុវត្ត។

ថ្ងៃសៅរ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០២៣

ព.រ.ល.២៣០៧.១៣៦៩

**បានប្រទាប់ព្រះរាជលញ្ឆករហើយ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
# សទ្ទានុក្រម

១- **ការចងក្រងស្ថិតិអត្រានុកូលដ្ឋាន** សំដៅដល់ដំណើរការនៃការបង្រួមនិងការសង្ខេបព័ត៌មានអំពីព្រឹត្តិការណ៍ជីវិតតាមរយៈការចាត់ថ្នាក់និងរៀបឡើងជាតារាងទិន្នន័យទៅតាមប្រភេទឬក្រុម ដើម្បីផលិតនូវស្ថិតិអត្រានុកូលដ្ឋានផ្អែកទៅតាមតារាងដែលត្រូវបានកំណត់ទុកជាមុន( Predetermined Tabulation )។

២- **កំណើតរស់** សំដៅដល់ការធាក់ចេញឬការទាញចេញពេញលេញនូវផលិតផលគភ៌ពីម្តាយ ដោយមិនគិតរយៈពេលនៃការមានគភ៌ ហើយបន្ទាប់ពីការបំបែកចេញពីម្តាយនោះ ទារកដកដង្ហើមឬបង្ហាញភស្តុតាងផ្សេងទៀតនៃជីវិត ដូចជាបេះដូងលោត មានជីពចរទងសុកឬសាច់ដុំមានចលនាជាក់លាក់ មិនថាទងសុកត្រូវបានកាត់ផ្តាច់ឬមានជាប់សុកមកជាមួយក្តី។

៣- **ទារកស្លាប់កើត** សំដៅដល់ការស្លាប់ទារកមុនពេលធ្លាក់ចេញឬទាញយកចេញទាំងអស់នូវទារកនិងសាខាទារក(ដូចជា សុក ទងសុក ទឹកភ្លោះ និងថង់ទឹកភ្លោះជាអាទិ៍ ) ពីផ្ទៃរបស់ម្តាយ ដោយមិនគិតរយៈពេលនៃការមានគភ៌។ ការស្លាប់នេះត្រូវបានស្តែងចេញឱ្យឃើញថាក្រោយការចាកចេញពីផ្ទៃម្តាយ ទារកនោះពុំមានដកដង្ហើមនិងពុំបង្ហាញឱ្យឃើញថាមានសញ្ញាជីវិតផ្សេងទៀត ដូចជាចង្វាក់បេះដូង ជីពចរទងសុកនិងចលនាសាច់ដុំ។

៤- **ទិន្នន័យអត្តសញ្ញាណបុគ្គល** សំដៅដល់ព័ត៌មាននានាដែលអាចកំណត់បានអត្តសញ្ញាណបុគ្គលណាម្នាក់។

៥- **បណ្តឹងមិនសុខចិត្ត** សំដៅដល់បណ្តឹងឧបាស្រ័យតាមផ្លូវរដ្ឋបាលរបស់បុគ្គលណាមួយដែលប្តឹងចំពោះការចាត់ចែង រួមទាំងសេចក្តីសម្រេចឬការយឺតយ៉ាវឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

៦- **ព័ត៌មានជីវមាត្រ** សំដៅដល់ការវាស់ស្ទង់លក្ខណៈជីវសាស្ត្រនិងលក្ខណៈផ្សេងទៀត មានដូចជាស្នាមខ្ទៅដៃ ប្រស្រីភ្នែក មុខ ហត្ថលេខាឬសំឡេងជាអាទិ៍ ដែលអាចប្រមូលបានដោយឌីជីថលនិងត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។

៧- **មរណភាព** សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នូវរាល់ភស្តុតាងនៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។

៨- **មូលដ្ឋានសុខាភិបាល** សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈនិងមូលដ្ឋានសុខាភិបាលឯកជន។

៩- **មូលដ្ឋានសុខាភិបាលសាធារណៈ** សំដៅដល់មន្ទីរពេទ្យជាតិ រួមទាំងមន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាលនិងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាពនិងប៉ុស្តិ៍សុខភាព។

១០- **មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី និងគ្លីនិកឯកជន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**១១- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព** សំដៅដល់ទម្រង់ដែលត្រូវបានបំពេញដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលច្បាប់បានកំណត់ ដើម្បីធ្វើការកត់ត្រានិងបញ្ជាក់អំពីមូលហេតុនិងប្រភេទនៃមរណភាព យោងតាមការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ ( International Classification of Diseases (ICD) )។

**១២- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល** សំដៅដល់លេខកូដសម្រាប់សម្គាល់របស់បុគ្គលម្នាក់ៗ។

**១៣- ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា** សំដៅដល់ស្ថានឯកអគ្គរាជទូត ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុល។

**១៤- ស្ថិតិអត្រានុកូលដ្ឋាន** សំដៅដល់ស្ថិតិអំពីព្រឹត្តិការណ៍ជីវិតរបស់ពលរដ្ឋ។

**១៥- សំបុត្រអត្រានុកូលដ្ឋាន** សំដៅដល់ឯកសារក្នុងទម្រង់ជាក្រដាសឬអេឡិចត្រូនិក ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានដែលមានព័ត៌មានដូចគ្នាទាំងស្រុងឬមួយផ្នែកនៃព័ត៌មាននៅក្នុងកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន ហើយក្រោយពេលបានចេញដោយមន្ត្រីអត្រានុកូលដ្ឋានរួចហើយ នឹងត្រូវមានអានុភាពនិងសុពលភាពពេញលេញដូចកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន។

**១៦- អត្តសញ្ញាណ** សំដៅដល់លក្ខណៈជាមូលដ្ឋាននៃអត្តសញ្ញាណបុគ្គល រួមមានឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត។

**១៧- អត្តសញ្ញាណខាងផ្លូវច្បាប់** សំដៅដល់លក្ខណៈជាមូលដ្ឋាននៃអត្តសញ្ញាណបុគ្គល រួមមានឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត ដែលបានផ្ដល់និងចេញដោយមន្ត្រីអត្រានុកូលដ្ឋានតាមរយៈការចុះបញ្ជីកំណើតរស់។ ក្នុងករណីដែលគ្មានការចុះបញ្ជីកំណើតរស់ អត្តសញ្ញាណស្របច្បាប់អាចត្រូវបានផ្ដល់ដោយអាជ្ញាធរអត្តសញ្ញាណកម្មដែលទទួលស្គាល់ដោយច្បាប់។

**១៨- អាសយដ្ឋានបច្ចុប្បន្ន** សំដៅដល់ទីតាំងលំនៅឋានដែលបុគ្គលកំពុងរស់នៅក្នុងភូមិសាស្ត្ររដ្ឋបាលជាក់លាក់ដូចមានលេខផ្ទះ ឈ្មោះផ្លូវ ក្រុម ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**១៩- អាពាហ៍ពិពាហ៍** សំដៅដល់កិច្ចសន្យាពិសេសដែលកើតចេញពីឆន្ទៈព្រមព្រៀងរវាងបុរសម្នាក់និងនារីម្នាក់ដែលមានបំណងរួមរស់ជាមួយគ្នានិងសង្គ្រោះគ្នាទៅវិញទៅមក ហើយបុរសនិងនារីនោះ ត្រូវតែមានលក្ខខណ្ឌដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

**២០- អ្នកតំណាងនៃលំនៅឋាន** សំដៅដល់បុគ្គលណាម្នាក់ដែលធ្វើជាអ្នកតំណាងនៃលំនៅឋាននោះក្នុងគោលបំណងនៃការចុះបញ្ជីស្នាក់នៅ។

**២១- អ្នករាយការណ៍** សំដៅដល់បុគ្គលឬស្ថាប័នដែលច្បាប់បានកំណត់ឱ្យរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអំពីព្រឹត្តិការណ៍ជីវិតដែលបានកើតឡើង និងផ្ដល់នូវរាល់ព័ត៌មាននិងចរិតលក្ខណៈទាំងអស់នៃព្រឹត្តិការណ៍នោះ សម្រាប់ជាមូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចធ្វើការចុះបញ្ជីព្រឹត្តិការណ៍នោះតាមផ្លូវច្បាប់។

**២២- ឯកជនភាព** សំដៅដល់ផ្នែកឯកជននៃជីវិតដែលបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារដោយច្បាប់។

**២៣- ឯកសារសម្គាល់ការស្នាក់នៅ** សំដៅដល់ឯកសាររដ្ឋបាលដែលប្រើប្រាស់ក្នុងគោលបំណងចុះបញ្ជីស្នាក់នៅនិងគ្រប់គ្រងមនុស្សគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកសារសម្គាល់ការស្នាក់នៅ អាចមានទម្រង់ជាសៀវភៅឬបណ្ណឬលិខិតបញ្ជាក់និងឯកសាររដ្ឋបាលផ្សេងទៀតដែលបញ្ជាក់ពីអាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលម្នាក់ឬច្រើននាក់។

